January-2008.qxd 1/18/2008 4:17 PM Page 1


CSC ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ទូរស័ព្ទ: ០២៣ ២២៤ ១២០

ថ្ងៃ០១-៣១ មករា ២០០៨

# អ្នកនាំសារ
The Messenger

ច្បាប់អនុញ្ញាតរបស់ក្រសួងព័ត៌មាន លេខ ១៨៣ ពមប្រក ២៥/មិថុនា/២០០៧ ។ *តម្លៃ១០០០រៀល* ០៦


**មាតិកា**




**ព្រះវិហារថ្មី! ក្រោយការចាប់ផ្ដើម ១៥ឆ្នាំ** ទំព័រ ៧





**ម៉ារីណោល! រួបរួមគ្នាអភិវឌ្ឍវប្បធម៌** ទំព័រ ៨

**ដាំត្រកួនឱ្យបានទិន្នផលល្អ** ទំព័រ ១២


# ឥវ៉ាន់ឡើងថ្លៃគឺជាកង្វល់ បន្ថែមរបស់កម្មករកាត់ដេរ

ទំព័រទី១០...




SIPAR

**សៀវភៅ ធ្វើអោយអ្នកចេះ**

មានលក់នៅតាមបណ្ណាគារ និងតូបលក់សៀវភៅនានា

023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ

**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : **FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍ ។
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍ ។
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:០០-១២:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់ ។
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ ។
ក្រុងព្រះសីហនុ : **FM 100.5 Mhz** ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍ ។

January-2008.qxd 1/18/2008 4:17 PM Page 2

# រូបថត



Photos : L. Sovanna

**ឆ្វេង :** លោកវ៉ាណេតូ ម៉ាទីណូ (ខាងឆ្វេងសម្តេចទេព វង្ស) ទីប្រឹក្សារបស់សម្តេចប៉ាបផ្នែកយុត្តិធម៌ និងសន្តិភាព ចូលជួបធ្វើសវនការជាមួយសម្តេចអគ្គមហាព្រះសង្ឃរាជ ទេព វង្ស ដើម្បីរឹតចំណងសហ-ប្រតិបត្តិការរវាងសាសនាទាំងពីរ នាថ្ងៃទី០៤ មករា ឆ្នាំ២០០៨

**ក្រោម :** សម្តេចសង្ឃប៊ូ គ្រី និងលោកអភិបាលអេមីល (ស្តាំ) ចូលរួមក្នុងសន្និសីទលើប្រធានបទ "លទ្ធិគ្រីស្ត-សាសនាក្នុងសង្គម" ឧទ្ទេសនាមដោយលោកកាឌីណាល់ម៉ាទីណូ នៅសណ្ឋាគារកាំបូឌីយ៉ាណា ក្រុងភ្នំពេញ នាថ្ងៃទី០៤ មករា ឆ្នាំ២០០៨

**ក្រោម :** ដំណើរទស្សនកិច្ចនៃលោកកាឌីណាល់ម៉ាទីណូ នៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រ និងវិទ្យាស្ថានកសិកម្មសន្តហ្វ្រង់ស្វ័រ នៅព្រះសហគមន៍កាតូលិក ចំការទៀង ស្រុកត្រាំកក់ បន្ទាប់ពីលោកធ្វើទស្សនកិច្ចនៅមន្ទីរពេទ្យព្រះកុមារយេស៊ូ មើលកម្មវិធីបងស្រីបុត្រីមេត្តាករុណាសន្តវ៉ាំងសង់ ដឺប៉ូល ក្នុងខេត្តតាកែវ និងក្រសួងមួយចំនួន។





**ក្រោម :** លោកកាឌីណាល់ម៉ាទីណូ និងលោកអគ្គរាជទូតសាលវ៉ាទំរ ពេណ្ណាស៊ីអូ ដាក់កម្រងផ្កា និងអធិដ្ឋានពីមុខឈើឆ្កាងលើដីមរណសាក្សីដែលបានស្លាប់សម័យប៉ុល ពត នៅតាំងគោក ខេត្តកំពង់ធំ



**ឆ្វេង :** លោកកាឌីណាល់ លោកអគ្គរាជទូត និងលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគទាំងបី រួមនិងបូជាចារ្យ បងស្រី និងសិស្សានុសិស្ស ក្នុងពិធីសម្ពោធភូមិគ្រឹះមាតានៃសន្តិភាពនៅខេត្តកំពង់ធំ នាថ្ងៃទី០៧ មករា ឆ្នាំ២០០៨





# វិចារណកថា

## ការលើកលែងទោស ជាមាគ៌ានៃសុភមង្គល



Photo : L. Sovanna

**លោកអន់តូនីសាមី ស៊ូសៃរាជ អភិបាលព្រះសហគមន៍កាតូលិកប្រចាំនៅភូមិភាគកំពង់ចាម**

នៅក្នុងឱកាសឆ្នាំថ្មីនេះ យើងខ្ញុំរួមចំណែកជាមួយបងប្អូនតាមបទពិសោធន៍ដែលយើងបានជួប ។ នៅក្នុងភូមិមួយនៃទឹកដីខេត្តកំពង់ចាម មានគ្រួសារពីរដែលកើតមានបញ្ហា ។ គ្រួសារទី១ ប្តីចូលចិត្តប្រើអំពើហិង្សាទៅលើប្រពន្ធ ចំណែកគ្រួសារទី២ ស្ត្រីជាប្រពន្ធរត់ចោលប្តី ។ ចំពោះគ្រួសារទី១ ប្តីរបស់គាត់ចូលចិត្តផឹកស្រា និងវាយធ្វើបាបប្រពន្ធរាល់ថ្ងៃក្រោមលេសស្រវឹងស្រា ។ ប្រពន្ធរបស់គាត់ទ្រាំមិនបាន ។ ស្ត្រីជាប្រពន្ធសម្រេចដោះស្រាយបញ្ហាយ៉ាងដូច្នេះ : ទី១ ជួបឪពុកម្តាយរបស់ប្តី សុំឱ្យជួយណែនាំ ព្រោះកូនប្រុសស្តាប់សំដីឪពុកម្តាយច្រើនជាង ។ ទី២ គឺលែងលះគ្នា ។ យើងបានជួបជាមួយបុរសជាប្តី និងពន្យល់រឿងនេះទៅគាត់ គឺទី១ គាត់ត្រូវរកវិធីណាដើម្បីសុំឱ្យឪពុកម្តាយរបស់ខ្លួន និងឪពុកម្តាយខាងស្រីជួយសម្រុះសម្រួល ។ ទី២ បើដោះស្រាយមិនបាន គឺចែកផ្លូវគ្នាតាមការស្នើសុំរបស់ប្រពន្ធ ។ ប៉ុន្តែបុរសជាប្តី បានជ្រើសរើសយកដំណោះស្រាយទី១ គឺគាត់ទៅនិយាយជាមួយប្រពន្ធគាត់ថា គាត់ឈប់ផឹកស្រា និងលែងប្រើហិង្សាទៀតហើយ ។ គាត់និយាយថា : "ខ្ញុំត្រូវព្យាយាមផ្តាច់ស្រា និងមិនប្រើអំពើហិង្សាដើម្បីឱ្យប្រពន្ធខ្ញុំមានជំនឿ និងទុកចិត្តខ្ញុំ ។ ចំនុចនេះធ្វើឱ្យយើងភ្ញាក់ផ្អើល ពីព្រោះវាជាវិធីល្អបំផុត ។ គ្រួសារទី២ ប្រពន្ធមានសាហាយ ហើយទៅជាមួយសាហាយបាត់ទៅ ។ បុរសជាប្តី បានប្រាប់យើងថា គាត់នឹងរង់ចាំនាងត្រលប់មកវិញ ហើយរួមរស់ជាមួយគ្នាជារៀងរហូត ។ គាត់បន្តថា គាត់នឹងលើកលែងទោសឱ្យនាង ដោយមិនប្រកាន់នូវកំហុសរបស់នាងឡើយ សំខាន់គឺធ្វើយ៉ាងណាឱ្យតែនាងវិលមកវិញ ។ ដូច្នេះឆ្លងតាមរយៈរឿងទាំងពីរខាងលើ យើងសូមរំឭកថា រឿងស្នេហាប្តីប្រពន្ធ គឺជារឿងមនោសញ្ចេតនា ដែលយើងត្រូវចេះរៀនសូត្រពីគ្នាទៅវិញទៅមក ជារៀងរាល់ពេលវេលាគឺរៀនយល់គ្នា អធ្យាស្រ័យគ្នា និងរៀនលើកលែងទោសឱ្យគ្នាទៅវិញទៅមកដើម្បីសុភមង្គលក្នុងគ្រួសារ ។

**លោកអភិបាលអន់តូនី**

**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120; E-mail : csccambodia@gmail.com; Website : www.catholiccambodia.org;

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្សីរ៉ាល់ដូ ។

ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា ។

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៦ ថ្មី ដែលពិពណ៌នាអំពីព្រះនាងម៉ារី ឡើងស្ថានបរមសុខ និងចម្រៀងកោតសរសើរព្រះនាង។ តម្លៃក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ប្រសិនប្រិយមិត្តមានចំណាប់អារម្មណ៍ សូមទំនាក់ទំនងទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មនឹងគិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។

**អង្គការមនុស្សលោកថ្មី** មានលក់សៀវភៅអប់រំសុខភាពមានចំណងជើង និងតម្លៃដូចជា: ការថែរក្សាខ្លួនប្រាណប្រចាំថ្ងៃ តម្លៃ ០,៨០ដុល្លារក្នុងមួយក្បាល។ សុខភាព និងអាហារូបត្ថម្ភ តម្លៃ ០,៩០ដុល្លារក្នុងមួយក្បាល។ អនាម័យបរិស្ថាន តម្លៃ ១,៥០ដុល្លារ ក្នុងមួយក្បាល។ ប្រព័ន្ធរំលាយអាហារ តម្លៃ ១,១០ដុល្លារ ក្នុងមួយក្បាល។ ប្រព័ន្ធដង្ហើម តម្លៃ ១,១០ដុល្លារ ក្នុងមួយក្បាល។ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ តម្លៃ ០,៩០ដុល្លារ ក្នុងមួយក្បាល។ ការការពារមុន និងក្រោយសម្រាលកូន តម្លៃ ០,៩០ ដុល្លារ ក្នុងមួយក្បាល។ បើត្រូវការ សូមទាក់ទងទូរស័ព្ទ : ០២៣ ៨៨២ ៣០៤។

តារាងនៅខាងស្តាំដៃនេះ គឺជាចម្លើយសម្រាប់ល្បែងប្រាជ្ញា នៅទំព័រទី ១៦ ។ ដូច្នេះប្អូនៗកុមារត្រូវទៅមើលល្បែងល្បងប្រាជ្ញានៅទំព័រនោះ រួចទើបមកមើលចម្លើយនៅទីនេះ ។



January-2008.qxd 1/18/2008 4:17 PM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

ថ្ងៃអាទិត្យទី៣ ក្នុងរដូវធម្មតា ( ថ្ងៃទី២៧ មករា ឆ្នាំ២០០៨)

## “ចូរប្រែចិត្តគំនិត ! ព្រះរាជ្យនៃស្ថានបរមសុខនៅជិតអ្នករាល់គ្នាហើយ”

( ម៉ាថាយ ៤,១២-២៣) លោកម៉ាថាយជាជនជាតិយូដា និពន្ធគម្ពីរដើម្បីពន្យល់ជំនឿព្រះសហគមន៍ឱ្យជនជាតិយូដាស្រួលស្ដាប់ ។ លោកម៉ាថាយចង់ពន្យល់ថា ព្រះយេស៊ូយាងមកតែងតាំង“ព្រះរាជ្យរបស់ព្រះជាម្ចាស់”នេះមែន តាមសេចក្ដីសង្ឃឹមរបស់ប្រជាជន ។ ប៉ុន្តែព្រះអង្គបានដូរអត្ថន័យ តាមព្រះយេស៊ូ ពាក្យ “ព្រះរាជ្យនេះ” មានន័យថាព្រះជាម្ចាស់យាងមក“គ្រងរាជ្យ” លើអស់អ្នកដែលសុខចិត្តទទួលព្រះអង្គទុកជាព្រះមហាក្សត្ររបស់ខ្លួន និងយកចិត្តទុកដាក់រស់នៅតាមរបៀបដែលគាប់ព្រះហឫទ័យព្រះអង្គ។ ព្រះអង្គយាងមកគ្រងរាជ្យលើមនុស្សគ្រប់ជាតិសាសន៍ ទោះបីអ្នកទាំងនោះកាន់សាសនាណាក៏ដោយ ។ ដូច្នេះយើងម្នាក់ៗត្រូវតែ “ប្រែចិត្ត” គឺលែងពឹងលើបុណ្យកុសលរបស់ខ្លួន ប៉ុន្តែយើងត្រូវតែផ្ញើជីវិតលើព្រះគ្រីស្ដ ដែលជាព្រះមហាក្សត្រ និងយាងមកត្រួតត្រាលើខ្លួនរបស់យើង ។

ថ្ងៃអាទិត្យទី ៤ ក្នុងរដូវធម្មតា ( ថ្ងៃទី០៣ កុម្ភៈ ឆ្នាំ២០០៨)

## “អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គល”

( ម៉ាថាយ ៥,១-១២) គ្រប់សាសនាប្រៀនប្រដៅមនុស្សឱ្យរកផ្លូវឆ្ពោះទៅកាន់សេចក្ដីសុខសាន្ត ។ ព្រះយេស៊ូប្រៀនប្រដៅប្រហាក់ប្រហែលនឹងព្រះពុទ្ធ ។ ព្រះពុទ្ធប្រោសសត្វដោយសម្ដែងអរិយសច្ចៈទាំងបួន ។ ព្រះបរមគ្រូឈ្វេងយល់ថា មនុស្សបានសេចក្ដីសុខ លុះត្រាតែខ្លួនចេះរំងាប់តណ្ហាដែលជាឫសនៃទុក្ខ ។ ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដាក់ចិត្តជាអ្នកក្រខ្សត់ មានចិត្តស្លូតបូត ទៀងត្រង់ មានមេត្តាករុណា និងយកចិត្តទុកដាក់កសាងសន្តិភាព ពិតជាបានសុភមង្គល ។ សុភមង្គលបែបនេះប្លែកពីរបៀបមនុស្សធម្មតាដែលចង់បានមែន ។ ព្រះអង្គមានព្រះបន្ទូលដែរថា “ត្បិតគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខហើយ !” មានន័យថាព្រះជា ម្ចាស់គ្រងរាជ្យលើគេ ។ ជីវិតគេមានអត្ថន័យថ្មី គឺគេរួមរស់ជាមួយព្រះបិតាក្នុងឋានៈជាបុត្រធីតារបស់ព្រះអង្គ ។ មានតែអ្នកជឿប៉ុណ្ណោះដែលអាចយល់សេចក្ដីទាំងនោះបាន !

ថ្ងៃអាទិត្យទី១ ក្នុងរដូវអប់រំពិសេស ( ថ្ងៃទី១០ កុម្ភៈ ឆ្នាំ២០០៨)

## “មនុស្សមិនរស់ដោយសារអាហារប៉ុណ្ណោះទេ គឺរស់នៅដោយសារគ្រប់ព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់”

( ម៉ាថាយ ៤,១-១១) ថ្ងៃអាទិត្យនេះយើងជាគ្រីស្ដបរិស័ទចាប់ផ្ដើម “រដូវអប់រំពិសេស” សែសិបថ្ងៃ ។ ព្រះសហគមន៍ចាត់ចែងអប់រំជំនឿគ្រីស្ដបរិស័ទ ដោយរំឭកយើងអំពីអត្ថបទសំខាន់ៗក្នុងព្រះគម្ពីរ ។ រៀងរាល់អាទិត្យ អត្ថបទទី១ រៀបរាប់ពីជំនឿបុព្វបុរសខាងជំនឿយើង អំពីព្រះជាម្ចាស់ត្រាស់ហៅយើងដូចលោកអាប្រាហាំជាគំរូនៃអ្នកជឿ អំពីព្រះអង្គសង្គ្រោះយើង ដូចទ្រង់សង្គ្រោះអ៊ីស្រាអែលពីជំនាន់ដើម អំពីព្រះអង្គជ្រើសរើសយើងជាគ្រីស្ដបរិស័ទដូចទ្រង់បានជ្រើសរើសព្រះបាទដាវីឌ-ល- ។ ដូច្នេះកុំប្រហែស! ចូរយកអត្ថបទគម្ពីរទាំងនោះមកអានរួមគ្នាក្នុងផ្ទះរិះគិតជាមួយគ្នា ។ សូមព្រះវិញ្ញាណព្រះយេស៊ូបំភ្លឺការរស់នៅរបស់ខ្លួន និងពង្រឹងជំនឿបងប្អូនផង ។

ថ្ងៃអាទិត្យទី២ ក្នុងរដូវអប់រំពិសេស ( ថ្ងៃទី១៧ កុម្ភៈ ឆ្នាំ២០០៨)

## “អ្នកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ចូរស្ដាប់លោកចុះ!”

( ម៉ាថាយ ១៧,១-៩) ជួនកាល មានគេចោទយើងថា ហេតុអ្វីបងប្អូនគោរពព្រះដែលស្លាប់ដូច្នេះ? តើព្រះយេស៊ូមានបាបឬបានជាគេឆ្កាងយ៉ាងសែនអាម៉ាស់ដូច្នេះ? ព្រះអង្គសង្គ្រោះមនុស្សលោកដូចម្ដេចកើត បើព្រះអង្គមិនបានសង្គ្រោះខ្លួនឯងផង? សំណួរទាំងនេះគឺត្រូវបានគេចោទតាំងពីព្រះសហគមន៍ដើមដំបូងមកម្ល៉េះ ។ គ្រីស្ដបរិស័ទពីដើមមិនហ៊ានគូសសញ្ញាឈើឆ្កាងព្រោះខ្មាសគេពេក ។ តាមអត្ថបទគម្ពីរ ដំណឹងល្អនៅថ្ងៃនេះ ជួយដោះស្រាយសេចក្ដីនេះ ។ ក្នុងគម្ពីរដំណឹងល្អនេះ ព្រះយេស៊ូក៏មានព្រះបន្ទូលតបថា ព្រះអង្គត្រូវគេមើលងាយត្រូវរងទុក្ខលំបាកនិងត្រូវសោយទិវង្គត់យ៉ាងសែនអាម៉ាស់ ។ សន្តម៉ាថាយដែលតែងអត្ថបទនេះ គឺចង់សម្ដែងនូវជំនឿរបស់ព្រះសហគមន៍ចំពោះព្រះយេស៊ូដើម្បីឱ្យអ្នកអានរឿងរបស់ព្រះគ្រូដែលរងទុក្ខយ៉ាងសែនអាម៉ាស់នោះ បានដឹងអំពីឋានៈរបស់ព្រះអង្គវិញ ។

## សម្រាប់កុមារ



សួស្ដីប្អូនៗ អ្នកនាំសារនឹងបង្ហាញរឿងរ៉ាវមួយចំនួនដែលទាក់ទងនឹងព្រះយេស៊ូដូចតទៅ :

**តើព្រះយេស៊ូទទួលពិធីជ្រមុជទឹកនៅទីកន្លែងណា ?**

នៅក្នុងគម្ពីររៀបរាងដោយលោកម៉ាថាយ បានសរសេរថា ព្រះយេស៊ូទទួលពិធីជ្រមុជទឹកនៅទន្លេយ័រដាន់ នៅពេលព្រះអង្គយាងចេញពីទឹកស្រាប់តែផ្ទៃមេឃបើកចំហ នៅពេលនោះ ព្រះអង្គបានឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងមកសណ្ឋិតលើព្រះអង្គមានរូងរាងដូចសត្វព្រាប។ ស្របពេលនោះក៏មានសូរសំឡេងថា : “ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ស្រឡាញ់ព្រះអង្គណាស់”។ កន្លែងនេះគឺបញ្ជាក់អំពីឋានៈរបស់ព្រះយេស៊ូ មុនពេលចេញទៅប្រកាសដំណឹងល្អដល់ប្រជាជន។

**តើអ្នកណាធ្វើពិធីជ្រមុជទឹកថ្វាយព្រះយេស៊ូ ?**

នៅក្នុងគម្ពីរ គេបានបញ្ជាក់យ៉ាងច្បាស់ថា លោកយ៉ូហាន បាទីស្ទ ជាអ្នកធ្វើពិធីជ្រមុជទឹកថ្វាយព្រះយេស៊ូ។ មុនពេលព្រះយេស៊ូយាងមកដល់ទន្លេយ័រដាន់នេះ លោកយ៉ូហាន បាទីស្ទ បានស្រែកប្រកាសនៅវាលរហោឋានឱ្យប្រជាជនកែប្រែចិត្តគំនិត និងរៀបចំផ្លូវថ្វាយព្រះជាម្ចាស់។ ដើម្បីអាចកែប្រែចិត្តគំនិតបាន គឺប្រជាជនទាំងនោះត្រូវមកទទួលពិធីប្រមុជទឹក។

**បន្ទាប់ពីទទួលពិធីជ្រមុជទឹកហើយមានរឿងអ្វីកើតឡើងជាមួយព្រះយេស៊ូ ?**

ក្រោយពេលទទួលពិធីជ្រមុជទឹករួចហើយ ព្រះយេស៊ូត្រូវមារ (វិញ្ញាណអាក្រក់) ល្បួងនាំទៅវាលរហោឋានអស់រយៈពេល ៤០ថ្ងៃ ៤០យប់។ នៅពេលនោះ ព្រះយេស៊ូទទួលរងនូវការល្បួងចំនួនបីដង។ ទី១ ពេលព្រះយេស៊ូអស់កម្លាំង មារបានល្បួងឱ្យព្រះយេស៊ូធ្វើការអស្ចារ្យ ប្រែដុំថ្មទៅនំប៉័ង ទី២ មារបាននាំព្រះយេស៊ូទៅលើដំបូលព្រះវិហារក្រុងយេរូសាឡឹម សុំឱ្យព្រះអង្គលោតចុះក្រោម វាថានឹងគ្មានគ្រោះថ្នាក់ បើព្រះអង្គពិតជាព្រះបុត្រាមែន និងទី៣ មារឱ្យព្រះយេស៊ូថ្វាយបង្គំវា វានឹងឱ្យព្រះអង្គគ្រប់គ្រងផែនដីទាំងមូល និងឱ្យទ្រព្យសម្បត្តិយ៉ាងច្រើនទៀត។ ប៉ុន្តែរាល់ពេលព្រះអង្គមិនធ្វើតាមវានោះឡើយ។ ដូច្នេះព្រះអង្គឈ្នះនូវការល្បួងរបស់មារនេះ។



# ព្រឹត្តិការណ៍ប្រចាំខែ



Photos: L. Samphors

## អគ្គិភ័យលេបត្របាក់ផ្សារលើនៅក្រុងព្រះសីហនុ

តូប និងស្តង់ចំនួន៩០០ នៃផ្សារលើក្រុងព្រះសីហនុ ត្រូវបានបំផ្លាញទាំងស្រុងដោយអគ្គិភ័យដ៏ធំមួយកាលពីដើមឆ្នាំ២០០៨ នៅវេលារំលងអធ្រាត្រ ថ្ងៃទី២ មករាកន្លងទៅ ។ មហន្តរាយនេះមិនបណ្ដាលឱ្យនរណាម្នាក់រងរបួសទេ ។ អាជីវករភាគច្រើន សង្ស័យថា អគ្គិភ័យនេះជាអំពើរបស់អាជ្ញាធរដែលមានបំណងចង់ដេញឱ្យពួកគេទៅលក់នៅទីតាំងថ្មី គឺមជ្ឈមណ្ឌលពាណិជ្ជកម្មក្រុងព្រះសីហនុ ។ ប៉ុន្តែរាល់ការចោទប្រកាន់របស់ក្រុមអាជីវករត្រូវបានអាជ្ញាធរក្រុងព្រះសីហនុបដិសេធ ។ ក្នុងបញ្ហានេះ ក្រុមអាជីវករចំនួន៣០០នាក់បានឡើង មកក្រុងភ្នំពេញនៅថ្ងៃបន្ទាប់ ដើម្បីសុំអន្តរាគមន៍ពីសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន ដែលពួកគេត្រូវបានរារាំង ជាច្រើនលើកច្រើនសាពីក្រុមនគរបាល ក្រុងភ្នំពេញ ។ ជាលទ្ធផលនៅថ្ងៃទី០៥ មករា អាជ្ញាធរ ក្រុងព្រះសីហនុបានប្រកាសថា សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានឧបត្ថម្ភប្រាក់ផ្ទាល់ខ្លួនចំនួន ២០ម៉ឺនដុល្លារ ដើម្បីជួយសាងសង់ដំបូលធំរបស់ផ្សារលើឡើងវិញ ហើយការដ្ឋានសាងសង់កំពុងដំណើរការនៅពេលនេះដែរ ។

## សារឆ្នាំថ្មីនៃសម្ដេចហ៊ុន សែន ចំពោះលោកយ៉ាសហ្គាយ

សម្ដេចហ៊ុនសែនបានអំពាវនាវជាថ្មីម្ដងទៀតដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ( អ.ស.ប) ឱ្យបញ្ជូនលោកយ៉ាសហ្គាយតំណាងពិសេសរបស់អ.ស.ប ផ្នែកសិទ្ធិមនុស្សនៅកម្ពុជាឱ្យទៅកាន់ប្រទេសកេនយ៉ា ជាប្រទេសកំណើតរបស់លោកដែលកំពុងរីករវដោយអំពើហិង្សា ក្រោយពេលបោះឆ្នោតជ្រើសរើសប្រធានាធិបតី ។ សម្ដេចនាយករដ្ឋមន្ត្រីចាត់ទុកថា នេះជាសារថ្មីរបស់លោកផ្ញើជូនអគ្គលេខា-ធិការអ.ស.ប និងលោកយ៉ាសហ្គាយដែលបានរិះគន់យ៉ាងខ្លាំងក្លាពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា កាលពីចុងឆ្នាំ២០០៧នេះ ។ សេចក្ដីអំពាវនាវនេះបាន ធ្វើឡើងកាលពីថ្ងៃទី ០៣ ខែមករា ក្នុងឱកាសសម្ពោធមន្ទីរពេទ្យយោធាភូមិភាគ២ នៅខេត្តកំពង់ចាម ។

## សម្ដេចឪសម្រេចបញ្ចប់អាជីពថតខ្សែភាពយន្ត

សម្ដេចនរោត្តមសីហនុសម្រេចព្រះហឫទ័យថា នឹងបញ្ចប់អាជីពជាអ្នកផលិតភាពយន្តរបស់ព្រះអង្គ ក្រោយពីមានមតិខ្លះបានរិះគន់ទៅដល់ការថតខ្សែភាពយន្តរបស់ព្រះអង្គ ដែលមានចំណងជើងថា “ម៉ូណាស៊ុយ៉ូ” ដែលបានថតកាលពីព្រឹកថ្ងៃទី០២ មករា នៅវិមានឯករាជ្យ ក្នុងរាជ-ធានីភ្នំពេញ ។ នៅក្នុងព្រះរាជសាររបស់សម្ដេចឪ ចុះផ្សាយថ្ងៃទី០៦ មករា ព្រះអង្គបានមានព្រះរាជចំណារថា : “មានអ្នកសារពត៌មាន និងកុមារខ្លះ បាននិយាយរិះគន់ខ្ញុំនរោត្តម សីហនុយ៉ាងខ្លាំង” ។ ព្រះអង្គបានដកស្រង់ឧទាហរណ៍ដែលបានចុះផ្សាយនៅក្នុងសារពត៌មាន **The Cambodia Daily** ថា កុមារខ្មែរមួយចំនួនបានរិះគន់ថា តួអង្គឈុតខ្មៅនៃកងទ័ពខ្មែរក្រហមក្នុងរឿងរបស់ព្រះអង្គទាំងនេះ មិនកាត់ដូចពួកខ្មែរក្រហមទាល់តែសោះ ។ ពួកគេស្លៀកពាក់ ខោអាវស្បែកជើង កវែងដ៏មានតម្លៃថ្លៃ រូបរាងស្រស់សង្ហារ ចេះសើចសប្បាយ និងចេះគួរសមគេឯង ។

## អាកាសធាតុ : សន្និសីទបាលី លទ្ធផលធូរស្រាល

ការចរចារយៈពេលពីរថ្ងៃដើម្បីឈានទៅរក... បន្ទាប់ពីប៉ុន្មានឆ្នាំនៃការចរចា ។ នេះគឺជាការសរុបលទ្ធផលពីសន្និសីទទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី ( កាលពីខែធ្នូ ឆ្នាំ២០០០៧) ។ អ្នកតំណាងមកពី១៨៧ប្រទេស ដែលមានវត្តមានបានព្រមព្រៀងទៅលើ “ផែនទីចង្អុលផ្លូវ” មុននឹងឈានទៅការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ២០០៩ នៅទីក្រុង **Copenhague** ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងការកើនកំដៅរបស់ផែនដីបន្ទាប់ពីមានពិធីសារទីក្រុងក្យូតូជាច្រើនឆ្នាំ ។
តាមរយៈនេះទោះបីប្រទេសទាំងអស់ ហាក់ដូចជាយល់អំពីភាពបន្ទាន់ចាំបាច់ក្នុងការថែរក្សាអាកាសធាតុ ប៉ុន្តែប្រទេសនីមួយៗ នៅការពារផលប្រយោជន៍ខ្លួនដែលនាំមុខដោយសហរដ្ឋអាមេរិក ។ ដូច្នេះលទ្ធផលមិនបានបំពេញចិត្តមនុស្សច្រើនទេ ។ ប៉ុន្តែទោះបីបញ្ហាសំខាន់ត្រូវបានគេលើកមកជជែកគ្នា តែការកំណត់តួលេខក្នុងការកាត់បន្ថយឧស្ម័នមិនទទួលបានការចម្រើនទេ ។ ទោះជាយ៉ាងនេះ ក៏មានកិច្ចព្រមព្រៀងទាក់ទងទៅនឹងការបង្កើតមូលនិធិពិភពលោក សម្រាប់ជនភៀសខ្លួនដោយសារអាកាធាតុសម្រាប់ភាពចាំបាច់នៃការបង្កើតព្រៃត្រូពិច និងការបង្កើតឱ្យមានប្រព័ន្ធស្រូបទាញឧស្ម័នកាបូនិក ។

## ប្រទេសថៃ : អ្នកស្និទ្ធថាក់ស៊ីនឈ្នះឆ្នោត

សកម្មជនគាំទ្រអតីតនាយករដ្ឋមន្ត្រីថៃ ថាក់ស៊ីន ស៊ីណាវ៉ាត្រា ដែលត្រូវបានបណ្ដេញចេញពីអំណាចកាលពីខែកញ្ញា ឆ្នាំ២០០៦ ដោយក្រុមឧត្ដមសេនីយ៍នោះ បានឈ្នះការបោះឆ្នោតនីតិបញ្ញត្តិកាលពីថ្ងៃអាទិត្យ ទី២៣ ធ្នូ ឆ្នាំ២០០៧ កន្លងទៅនេះ ។ គណបក្សអំណាចប្រជាជន ទទួល ២២៨អាសនៈ ក្នុងចំណោមអាសនៈ ៤៨០ក្នុងរដ្ឋសភា បន្ទាប់ពីរាប់បាន ៩៣% នៃសម្លេងឆ្នោត នៅខណៈពេលគណបក្សប្រឆាំងសំខាន់បំផុតទទួលបាន ១៦២សម្លេង ។ គណបក្សអំណាចប្រជាជនបានប្រកាសនៅថ្ងៃច័ន្ទបន្ទាប់ថា បានរួបរួមជាសម្ព័ន្ធមិត្តជាមួយគណបក្សតូចៗបីទៀតដើម្បីបង្កើតរដ្ឋាភិបាលមួយដែលត្រូវការ ២៥៤អាសនៈនៅក្នុងរដ្ឋសភា ។ ជាមួយគ្នានេះដែរ គណៈកម្មការរៀបចំការបោះឆ្នោតថៃ បានប្រកាសនៅថ្ងៃព្រហស្បតិ៍បន្ទាប់ថា នៅថ្ងៃ ០១ មករា ឆ្នាំ២០០៨ និងមានការស៊ើបអង្កេតចោទប្រកាន់ពីការបន្លំសន្លឹកឆ្នោតដែលសំដៅទៅលើបេក្ខជនជាប់ឆ្នោតចំនួន ៨៣នាក់ ដែលក្នុងនោះ មាន៦៥នាក់ មកពីគណបក្សអំណាចប្រជាជន ។ ចំណែកលោកថាក់ស៊ីន ស៊ីណាវ៉ាត្រា បានប្រកាសថា លោកគិតចង់ត្រឡប់មកប្រទេសថៃវិញ នាខែមេសា ឆ្នាំ ២០០៨ ។ តើក្រុមឧត្ដមសេនីយ៍នឹងធ្វើអ្វី ?

January-2008.qxd 1/18/2008 4:18 PM Page 6

# ព័ត៌មានព្រះសហគមន៍កាតូលិក

## ជំរុញយុវជនយល់ដឹងពីការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទ

**អាគីប**

អង្គការការិតាសជំរុញយុវជនឱ្យយល់ដឹងពីការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទ ដោយលើកយកប្រធានបទចំនួន៣ មកពិភាក្សាក្នុងវេទិកាយុវជនមួយនៅការិយាល័យអង្គការការិតាសខេត្តកណ្តាល នាព្រឹកថ្ងៃទី៩ មករា ដែលមានការចូលរួមពីសំណាក់មន្ត្រីអង្គការពាក់ព័ន្ធ បុគ្គលិកអង្គការការិតាស និងយុវជនប្រមាណជិត ១០០នាក់។ ប្រធានបទសំខាន់នៅក្នុងវេទិកានេះគឺ "ជំនាញវិជ្ជាជីវៈរបស់យុវជន និងការប្រឈមមុខចំពោះការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ"។ វេទិកានេះមានគោលបំណងសំខាន់បី គឺលើកកម្ពស់ការយល់ដឹងអំពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទឱ្យបានច្បាស់ ចង់ឱ្យយុវជនមានចំណាប់អារម្មណ៍ខ្ពស់ទៅលើជំនាញវិជ្ជាជីវៈ និងប្រមែប្រមូលយុវជនឱ្យចូលរួមយ៉ាងសកម្ម ដើម្បីបង្ការទប់ស្កាត់បញ្ហាផ្សេងៗ ដែលទាក់ទងនឹងកម្លាំងពលកម្ម និងការជួញដូរផ្លូវភេទ។ លោកនុត សំអុល ជានាយកប្រតិបត្តិអង្គការការិតាសកម្ពុជា បានឱ្យដឹងថា: "មូលហេតុដែលយើងរៀបចំឱ្យមានសិក្ខាសាលានេះឡើង គឺចង់បង្ហាញពីឆន្ទៈរបស់យើងដើម្បីកាត់បន្ថយ ឬចង់បញ្ចប់នូវការជួញដូរលើគ្រប់សកម្មភាព"។



Photo: A KEUP

យុវជន យុវនារី ជួបប្រជុំគ្នា ថតរូបទុកជាអនុស្សាវរីយ៍ នៅពេលពួកគេបានមកចូលរួមក្នុងវេទិកាយុវជនដ៏មានសារៈប្រយោជន៍ អំពីការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទ

## "ចូរយើងរស់ក្នុងក្តីស្រឡាញ់"

**ឡុង សម្ផស្ស**

នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) មានរៀបចំអភិបូជាអរព្រះគុណព្រះជាម្ចាស់ ក្នុងឱកាសអបអរគម្រប់ខួប ៤៦ឆ្នាំ នៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យរបស់លោកអភិបាលអេមីល ដេតម្ប។
នៅក្នុងឱកាសនោះ មានការអញ្ជើញជាអធិបតីភាព និងការថ្វាយអភិបូជាពីសំណាក់លោកអភិបាលអេមីល ដេតម្ប ព្រមទាំងមានការចូលរួមពីលោកបូជាចារ្យ បងប្រុស បងស្រី និងបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។
លោកអ៊ឹង ទ្រី តំណាងគណៈកម្មការ និងបងប្អូនគ្រីស្តបរិស័ទនៃព្រះសហគមន៍សន្តយ៉ូសែប បានថ្លែងថា: "ព្រះជាម្ចាស់បានត្រាស់ហៅលោកអភិបាល មកធ្វើជាគង្វាលដ៏ល្អ ចំណែកលោកក៏បានបំពេញមុខងារនេះដោយសេចក្តីស្រឡាញ់ និងជំនឿ។ដូច្នេះតាំងនាមឱ្យគ្រីស្តបរិស័ទទាំងអស់ សូមព្រះជាម្ចាស់ប្រទានពរ ឱ្យលោកអភិបាលបានប្រកបដោយសុខភាពល្អ និងអាយុយឺនយូរ។
ចំណែកលោកអភិបាលអេមីល ដេតម្ប មានប្រសាសន៍ថា: "ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានត្រាស់ហៅខ្ញុំ និងបងប្អូន ដែលចូលរួមនៅថ្ងៃនេះ។ លោកបានសង្កត់ធ្ងន់ថា សូមយើងទាំងអស់គ្នារស់នៅក្នុងសេចក្តីស្រឡាញ់ដែលបង្ហាញថាយើងសុខចិត្តដើរតាមព្រះយេស៊ូ។



Photo: L. Samphors

គ្រីស្តបរិស័ទជូនផ្កាទាំងអំណរសប្បាយដល់លោកអភិបាលអេមីល ដេតម្ប ក្នុងគម្រប់ខួបលើកទី៤៦ឆ្នាំ នៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យរបស់លោក

## បុណ្យព្រះយេស៊ូប្រសូតនៅគីរីវង្ស

គីរីវង្ស គឺជាព្រះសហគមន៍ថ្មីមួយ ដែលទើបលេចឡើង នឹងកំពុងតែមានការរីកចម្រើនគួរឱ្យស្ញើចសរសើរ ក្រោមការដឹកនាំរបស់លោកបូជាចារ្យអូលីវីយេ។ កាលពីថ្ងៃអាទិត្យ ទី២៣ ធ្នូ ឆ្នាំ ២០០៧ កន្លងទៅនេះ មានប្រារព្ធធ្វើពិធីបុណ្យព្រះយេស៊ូប្រសូត។ នាពេលរសៀលក្រុមកាយឫទ្ធិ និងក្មេងៗ ៣១៨នាក់ បានលេងល្បែងជាច្រើនយ៉ាងសប្បាយរីករាយជាមួយគ្នា ព្រមទាំងលោកបូជាចារ្យ និងបងស្រីផងដែរ។ បន្ទាប់មកលោកបូជាចារ្យអូលីវីយេ បានចែកកាដូដល់ក្មេងៗ។ នៅវេលាម៉ោង ៣:៣០ មានពិធីអភិបូជា ដែលមានលោកយាយ លោកតា យុវជន យុវនារី និងមានសិស្ស និងនិស្សិតមកពីភ្នំពេញ ចំការទៀង និងកំពត។ ក្រោយពេលចប់ពិធីអភិបូជា លោកបូជាចារ្យអូលីវីយេ បានចែកអំណោយដល់ចាស់ៗ ចំនួន៦០នាក់ ក្នុងនោះរួមមានមុងមួយ ភួយមួយ កន្សែងមួយ មី និងសាប៊ូ ព្រមទាំងបានរៀបចំការីនំប៉័ង សម្រាប់ទទួលពួកគាត់ និងបងប្អូនទាំងអស់ ដែលបានមកចូលរួមនៅក្នុងពិធីបុណ្យ។ លុះដល់យប់ឡើងយុវជន យុវនារីគីរីវង្ស បានសម្តែងសិល្បៈអំពីព្រះយេស៊ូប្រសូត និងមានកម្មវិធីផ្សេងៗ ជាច្រើនទៀត។ សុភា



# យុវជន

## ព្រះវិហារថ្មី ! ក្រោយការចាប់ផ្តើម ១៥ឆ្នាំ

**លី សុវណ្ណា**

គ្រីស្តបរិស័ទកាតូលិកនៅប្រទេសកម្ពុជា បានជួបជុំគ្នាឡើងវិញបន្ទាប់ពីសម័យសង្គ្រាមនិងការសម្លាប់រង្គាលដ៏ព្រៃផ្សៃបានរលត់ទៅ ដូចជាព្រះសហគមន៍កាតូលិកបឹងទំពុន ក្នុងខណ្ឌមានជ័យ ទីក្រុងភ្នំពេញ បានចាប់កំណើត នាដើមទសវត្សរ៍ទី៩០ ដោយបងប្អូនខ្មែរ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីព្រំដែនខ្មែរ-ថៃ។ នៅពេលចាប់ផ្តើម បងប្អូនក៏បានជួបជុំគ្នា និងយកផ្ទះធ្វើជាព្រះវិហារអស់រយៈពេល ១៥ឆ្នាំ ។
នៅថ្ងៃទី៦ មករា ឆ្នាំ២០០៨ កន្លងទៅនេះ ព្រះសហគមន៍បឹងទំពុន បានបើកសម្ពោធព្រះវិហារ ដ៏ធំក្រោមអធិបតីភាពរបស់លោកម៉ាទីណូ ប្រធានទីប្រឹក្សា សម្តេចប៉ាបទទួលបន្ទុកផ្នែក យុត្តិធម៌ និងសន្តិភាព លោកអគ្គរាជទូត សម្តេចប៉ាប ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកអភិបាលព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ។ ព្រះវិហារថ្មីក៏ត្រូវបានប្រសិទ្ធនាមថា: "ព្រះវិហារព្រះកុមារយេស៊ូ"។ ក្នុងឱកាសនោះ មានអ្នកចូលរួមប្រហែល ១000 នាក់ ទាំងភ្ញៀវជាតិ និងអន្តរជាតិ។ លោកម៉ាទីណូ មានប្រសាសន៍ក្នុងឱកាសនោះថា ព្រះវិហារថ្មីដែលសម្ពោធនេះ គឺជាសញ្ញាសម្គាល់ខាងក្រៅនូវបំណងប្រាថ្នា ដែលព្រះសហគមន៍មានជំនឿ ចង់ប្រកាសថា ព្រះកុមារយេស៊ូដែលប្រសូតពីព្រះនាងម៉ារីបានរំដោះយើង និងប្រទានឱ្យយើងទទួលនូវជីវិតពេញបរិបូរ។ ដូច្នេះនៅថ្ងៃនេះផងដែរ សូមឱ្យយើងយកតង្វាយមកថ្វាយព្រះអង្គ ទឹកចិត្តស្រឡាញ់ព្រះអង្គ និងស្រលាញ់បងប្អូនផ្សេងៗទៀត។ បន្ទាប់អំពីពិធីបុណ្យបានបញ្ចប់ លោកបូជាចារ្យម៉ារីយ៉ូ អ្នកទទួលខុសត្រូវព្រះសហគមន៍កាតូលិកបឹងទំពុននេះ បានបង្ហាញពីអារម្មណ៍រំភើបយ៉ាងខ្លាំងថា: "ខ្ញុំសប្បាយខ្លាំងណាស់"។ ក្នុងព្រះវិហារថ្មីនេះ មានបញ្ចុះអដ្ឋិធាតុសន្តបុគ្គលពីររូប នៅលើអាសនៈ គឺសន្តនីកាដូ ម៉ារីយ៉ាមពុយរ និងសន្តពីយ៉ូមកពីយេត្រាលស៊ីណា ប្រទេសអ៊ីតាលី។ លោកបូជាចារ្យម៉ារីយ៉ូ ក៏ពន្យល់ថា: "ការបញ្ចុះអដ្ឋិធាតុនេះមានន័យថា យើងអង្វរព្រះជាម្ចាស់តាមរយៈសន្តបុគ្គលដែលបានឡើងលើស្ថានបរមសុខហើយនោះ"។
ចំណែកអ្នកស្រីងួន ផល្លា ជាសមាជិកគណៈកម្មការរៀបចំពិធីបុណ្យនៅក្នុងព្រះសហគមន៍បឹងទំពុន ក៏បានសម្តែងអារម្មណ៍ថា: "ថ្ងៃនេះ ខ្ញុំរំភើបណាស់" ពីព្រោះវាជាពេលវេលា ដែលយើងរំពឹងជាយូរមកហើយ។ ថ្ងៃនេះក៏ជាពេលវេលាជួបជុំបងប្អូនគ្រីស្ត-បរិស័ទ គ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។ នេះជាកិត្តិយសសម្រាប់ព្រះសហគន៍កាតូលិក បឹងទំពុនដែរ ដែលមានលោកទីប្រឹក្សាសម្តេចប៉ាប និងលោកអគ្គរាជទូតបានអញ្ជើញមកចូលរួម។
ព្រះវិហារថ្មីនេះ ជាក្តីសង្ឃឹមថ្មីរបស់ព្រះសហគមន៍កាតូលិក និងជួយឱ្យជំនឿរបស់យើងរីកចម្រើន។




### សាងសង់ព្រះវិហារព្រះកុមារយេស៊ូ

ព្រះវិហារព្រះកុមារយេស៊ូនៃព្រះសហគមន៍កាតូលិកបឹងទំពុនជាព្រះវិហារធំដំបូងគេនៅភ្នំពេញ បន្ទាប់ពីការចាប់ផ្តើមឡើងវិញអស់រយៈពេល ១៥ឆ្នាំ។ ការកសាងព្រះវិហារនេះចំណាយអស់ទឹកប្រាក់ប្រមាណជា ២៧០ ០០០ ដុល្លារអាមេរិក។ ទឹកប្រាក់ទាំងនេះបានមកពីសប្បុរសជននានា សមាគមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស (MEP) គ្រឹះស្ថានសម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME) ក្រសួងសម្រាប់នាំដំណឹងល្អនៃប្រជាជាតិនានា ... ប៊ុរីវ៉ាទីកង់ មូលនិធិឡាំប្រ៊ីយ៉ាណា បងប្អូនគ្រីស្តបរិស័ទបឹងទំពុន ព្រះវិហារសន្តអាំប្រ៊ូសមកពីប្រទេសអ៊ីតាលី ព្រះវិហារអន្តរជាតិភ្នំពេញ ព្រះអង្គម្ចាស់ហ្វូរេស សាលរីយ៉ាទី និងសមាគមផ្សេងៗទៀតជាច្រើនផងដែរ។

ព្រះវិហារព្រះកុមារយេស៊ូបឹងទំពុនត្រូវបានសម្ពោធឡើងក្រោមបរិយាកាសយ៉ាងសប្បាយរីករាយ ដែលបញ្ជាក់អំពីជំនឿដ៏មុតមាំ និងសាមគ្គីភាពដ៏ប្រពៃរបស់គ្រីស្តសាសនិក







Photos: L. Sovanna

January-2008.qxd 1/18/2008 4:18 PM Page 8

## អង្គការ

# ម៉ារីណុល ! រួបរួមគ្នាអភិវឌ្ឍ វប្បធម៌

### អត្ថបទដោយអាគឹប



Photos : L. Samphors

អង្គការម៉ារីណុលមានកម្មវិធីគូរ
គំនូរដើម្បីពង្រឹងសកម្មភាពយុវជន

សំឡេងខ្យល់បក់ឮសូរវិច១ ប៉ះនឹងស្លឹកឈើ ពណ៌ខៀវស្រងាត់ នៅមុខផ្ទះដ៏តូចមួយ ស្ថិតក្នុងមណ្ឌលពន្លកនៃក្ដីសង្ឃឹមរបស់អង្គការម៉ារីណុល ។សំឡេងចម្រៀងយ៉ាងពិរោះរណ្ដំ ដែលបន្លឺឡើងក្បែរយុវជនមួយរូប ដែលកំពុងអង្គុយផ្ចង់ស្មារតី យ៉ាងយកចិត្តទុកដាក់ដើម្បីបញ្ចប់នូវរូបគំនូរមួយផ្ទាំងរបស់លោក ដោយពុំងាកទៅកាន់កន្លែងផ្សេង១ឡើយ ។ ក្រោយពីទំនេរដៃបន្តិចមក លោកចាន់សោភ័ណ្ឌជាជាងគំនូរប្រចាំមណ្ឌលពន្លកនៃក្ដីសង្ឃឹម ក៏បានងាកមកមានប្រសាសន៍ថា : "មណ្ឌលនេះ មានបើកវគ្គបណ្ដុះបណ្ដាលផ្នែកគូរគំនូរទៅដល់ក្មេង១តាំងពីឆ្នាំ ២០០៣មក" ។ លោកបានបន្តទៀតថា កម្មវិធីនេះ គឺអង្គការធ្វើឡើងក្នុងមួយវគ្គ តែ ៣ខែប៉ុណ្ណោះ គឺក្នុងពេលដែលសិស្សវិ៉ាកងជារៀងរាល់ឆ្នាំ។ លោក ភោគ វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធីពន្លកនៃក្ដីសង្ឃឹម មានប្រសាសន៍ឱ្យដឹងដែរថា : "ការគូរគំនូរនេះជាកម្មវិធីមួយដែលយើងភ្ជាប់នឹងកម្មវិធីសិក្សាអប់រំ និងគោលបំណងដែលអង្គការបង្កើត ឱ្យមាននូវកម្មវិធីគូគំនូរវគ្គខ្លី១នេះគឺដើម្បីបង្ហាញឱ្យក្មេង១ស្គាល់ថា នេះជាពណ៌អ្វីការប្រើពណ៌នោះយ៉ាងម៉េចតែប៉ុណ្ណោះ" ។ លោកបន្ថែមទៀតថា អ្វីដែលយើងបង្កើតនេះ យើងពុំចង់ឱ្យក្មេង១ទាំងនេះ យកពេលវេលាទំនេររបស់ពួកគេ ទៅដើរលេង សេពគ្រឿងញៀន ឬក៏ធ្វើអ្វីដោយគ្មានប្រយោជន៍នោះទេ ។ វគ្គគំនូរនេះបង្កើតឡើងបានចំនួន៤វគ្គ ដែលមួយវគ្គ១មានសិស្សជាង២០នាក់ ដែលមានអាយុចាប់ពី១២ឆ្នាំឡើងទៅ ។ លោកវុទ្ធីបានឱ្យដឹងដែរថា ជាមួយកម្មវិធីនេះ យើងមានការសប្បាយរីករាយពីព្រោះរៀងរាល់ឆ្នាំ មានយុវជនមកពីរដ្ឋកាលីហ្វ័រញ៉ា មកជួយក្នុងការគូររូបនេះផងដែរ ។ កំពុងអង្គុយកាត់ក្រដាសជាមួយមិត្តភ័ក្ដិ កុមារាវីរ៉ាវុធ អាយុ១៤ឆ្នាំបាននិយាយថា រូបគេបានរៀនគូរគំនូរ តាំងតែពីឆ្នាំ ២០០៦ ដែលមានរយៈពេល ២ខែ ប៉ុន្តែ ពេលនេះរូបគេភ្លេចអស់ហើយ ។ ចំណែកយុវជនរឿង ត្រែង អាយុ១៨ឆ្នាំ ដែលជាអតីតសិស្សនៅទីកន្លែងនោះបានលើកឡើងផងដែរថា: "ការគូរមានការពិបាក តែចំពោះអ្នកមានដុងគឺមិនពិបាកទេ" ។

## ចាន់ សោភ័ណ្ឌ : "នេះគឺជានិស្ស័យពីកំណើតរបស់ខ្ញុំ"

សោភ័ណ្ឌបានរៀនគូរគំនូរនាឆ្នាំ២០០០ ដែលទទួលបានការឧបត្ថម្ភពីអង្គការការីតាស ឱ្យចូលរៀននៅសាលារចនារយៈពេល ៣ឆ្នាំ ។ យុវជន វ័យ២៣ឆ្នាំរូបនេះ ជាជាងគំនូរ ជាគ្រូគំនូរ និងក៏ជាគ្រូបង្ហាត់រាំរបាំមួយរូបនៅក្នុង មណ្ឌលពន្លក នៃក្ដីសង្ឃឹមរបស់អង្គការម៉ារីណុលផងដែរ ។

យុវជនសោ ភ័ណ្ឌ និយាយថា : "នៅពេលទំនេរ ជាទម្លាប់ ខ្ញុំចូលចិត្តគូរគំនូរ និងស្ដាប់ចម្រៀង" ។ គេមានលក្ខណៈខុសគេ ដូចជានៅពេលដែលគេគូររូបអ្វីមួយដូចជារូបរបាំ លោកតែងស្ដាប់បទបុរាណ ឬបទអ្វីដែលហាក់ដូចជាបង្ហាញរូបទេពអប្សរា ដែលធ្វើឱ្យលោកមានអារម្មណ៍ថា កំពុងតែមានរូបស្រីរាំនៅពីខាងមុខ។ ប្រសិនបើលោកគូររូបសត្វ លោកចូលចិត្តស្ដាប់ចម្រៀង ដែលមានជាសំឡេងសត្វយំ ដែលធ្វើឱ្យលោក ហាក់ដូចជាស្ថិត នៅកណ្ដាលព្រៃភ្នំ និងបទភ្លេងទាំងនោះធ្វើឱ្យលោកមានអារម្មណ៍មូល គូរបានលឿន និងល្អស្អាត។ សព្វថ្ងៃលោកជា



យុវជនចាន់ សោភ័ណ្ឌ

និស្សិតឆ្នាំទី២នៃមហាវិទ្យាល័យសិល្បៈសូនរូប ។ ហើយមុនពេលលោកចូលរៀននៅមហាវិទ្យាល័យ គឺលោកចេះគូខ្លះ១ ដោយគ្មានគ្រូ ។ សោភ័ណ្ឌរៀបរាប់ពីបទពិសោធន៍កាលពីនៅវ័យកុមារថា គឺឱ្យតែមានកន្លែងដីទំនេរ លោកចូលចិត្តគូររូបភាពផ្សេង១លើនោះដោយមិនមានការធុញទ្រាន់ ។ ជាលទ្ធផលលោកក៏បានប្រលងជាប់ជ័យលាភីលេខមួយទូទាំងប្រទេស ខាងផ្នែកគំនូរ កាលពីលោកនៅរៀនថ្នាក់ទី១០ ហើយចាប់តាំងពីលោកចេះគូរមក លោកគូរគំនូរបានប្រមាណជាង២០០រូប ហើយចំពោះរូបគំនូររបស់លោក ចំនុចដែលធ្វើឱ្យអ្នកមើល គេមានចំណាប់អារម្មណ៍ និងចំនុចដែលល្អបំផុត គឺនៅត្រង់កែវភ្នែក និងលើបបូរមាត់របស់គំនូរដ៏រស់រវើក ។



## យុវជន

# អំនានរំលែក ការកំសាន្ត

### អង្គការស៊ីប៉ា



ទាំងម្ដាយ និងកូនស្រី កំពុងអានសៀវភៅយ៉ាងយកចិត្តទុកដាក់

Photos: Sipar

អ្នកស្រីហេង ស្រី និងកុមារីល្មៀង អាលីហ្សា ចូលចិត្តអានខ្លាំងណាស់ ។ អ្នកទាំងពីរមិនដែលស្មានថានឹងអាចមកនៅក្នុងបណ្ណាល័យCET ក្នុងភូមិចំការហ្លួង ខេត្តកំពង់ស្ពឺ របស់ពួកគេជាមួយគ្នាយ៉ាងនេះទេ ។ គេមានទម្លាប់ដ៏សាមញ្ញរៀង១ខ្លួន ។

គ្មានថ្ងៃណាមួយ គឺតាំងពីពេលបណ្ណាល័យនេះបើកទ្វារកាលពីឆ្នាំ២០០៥ ដែលអាលីហ្សា ឥឡូវ អាយុ ១១ឆ្នាំ មិនមកបណ្ណាល័យនេះទេ នាពេលសម្រាកទំនេរ ។ នាងពុំខ្ចីសៀវភៅ តែបានអានយ៉ាងរហ័សនៅនឹងកន្លែងផ្ទាល់ជាមួយនិងថាមពលជាក្មេងវ័យជំទង់ ។ ផ្ទុយពីនេះអ្នកស្រីហេង ស្រីម៉ៅ អាយុ៣១ឆ្នាំ ជាម្ដាយអេលីហ្សា មិនដែលមកអានសៀវភៅនៅពេលមានមនុស្សច្រើននោះទេ។ គាត់មកកាន់បណ្ណាល័យពីរ ឬបីដង ក្នុងមួយខែដើម្បីប្ដូរយកនូវសៀវភៅអានថ្មី១ ។ គាត់ចូលចិត្តអានយ៉ាងជក់ចិត្តនៅផ្ទះនាពេលល្ងាច នៅពេលដែលមនុស្សម្នាទាំងឡាយទៀតគេងលក់ស្កប់ស្កល់អស់ ។

ប៉ុន្តែថ្ងៃនេះ ម្នាក់១ បានរកឃើញនៅពេលអាននូវភាពស្និទ្ធស្នាលមួយ ហើយគ្មាននរណាចង់រំខានគេផ្សេងទៀតដែរក្នុងចំណោមម្ដាយកូនទាំងពីរនាក់នេះ នៅពេលដែលអ្នកទាំងពីរស្ថិតនៅក្នុងបណ្ណាល័យជាមួយគ្នា។ អ្នកស្រីហេង ស្រីម៉ៅ រៀបរាប់ថា: "ខ្ញុំមិនព្យាយាមផ្ដល់ដំបូន្មាន ដល់អាលីហ្សាទេ ទោះបីជាយ៉ាងណា នាងចូលចិត្តការអានដោយខ្លួនឯង។ ប៉ុន្តែនៅពេលដែលគេនិយាយពីការអានសៀវភៅទាំងនេះទៅកាន់ក្មេងមួយចំនួនដែលស្ថិតក្នុងវ័យស្រករនាង ពួកគេក៏បាននិយាយមកវិញថា វាដូចជាហួសសម័យបន្តិច..."

នៅខណៈដែលអាលីហ្សា ចូលចិត្តសៀវភៅរូបភាពរឿងព្រេងប្រពៃណី និងរឿងប្រលោមលោកខ្លី១ ម្ដាយរបស់នាងនិយាយថា ចូលចិត្តសៀវភៅក្បួនតម្រាដែលអប់រំសីលធម៌ ដូចជាគោលសីលធម៌ពុទ្ធសាសនា និងការនិទានពីខ្សែជីវិតនៃព្រះសាមណគោត្តមជាដើម ។ ក្នុងដៃទាំងពីររបស់គាត់មានកាន់សៀវភៅប្រលោមលោកជាច្រើន ដូចជា រឿងគង្គានិងផ្កាកូលាប ដែលបញ្ជាក់ពីការនិយមរបស់គាត់ ។ គាត់សារភាពថា: "ខ្ញុំចូលចិត្តសៀវភៅនិយាយអំពីបញ្ហាមនោសញ្ចេតនា និងបញ្ហាគ្រួសារ"ដូចក្នុងដៃគាត់បង្ហាញនូវសៀវភៅមួយ ដែលគាត់ទើបនឹងរកបាន និងមានចំណងជើងថា "ស្ពាយថ្នាល់ស្ដាំ" ដែលជាការពណ៌នាពីរឿងពិតនៃស្នេហាបរាជ័យមួយ ។ រឿងប្រលោមលោកនេះ គឺបានបញ្ចប់ដោយក្ដីទុក្ខសោក ដែលជួនកាលក៏ធ្វើឱ្យគាត់នឹកឃើញដល់ខ្សែជីវិតមនោសញ្ចេតនាផ្ទាល់ខ្លួនគាត់ ។ គាត់រៀបរាប់រឿងសម្ងាត់ផ្ទាល់ខ្លួនថា : "ប្ដីរបស់ខ្ញុំមិនយល់អំពីការលំបាកខ្ញុំ ជាស្ត្រីភេទទេ ។ ខ្ញុំធ្វើការ ចំណែកគាត់មិនធ្វើអ្វីទាំងអស់" ។ គាត់កំពុងពរពោះ អាលីហ្សាពេលដែលគ្រួសារគាត់លែងលះគ្នា បន្ទាប់មកគាត់ត្រូវថែរក្សាម្ដាយគាត់ដែលមានជំងឺ ក្នុងសភាពខ្លួនឯងជាស្ត្រីមេម៉ាយអស់រយៈពេលជាច្រើនឆ្នាំ ។ ស្ត្រីទាំងបីបង្កើតបានជាគ្រួសារតូចមួយ ជួយគ្នាទៅវិញទៅមក និងរួមសាមគ្គីគ្នា ។ លោកយាយចាស់ ជាងគេមិនចេះអក្សរទេ តែកូនរបស់គាត់ និងចៅរបស់គាត់អានឱ្យគាត់ស្ដាប់ ។ អ្នកស្រីហេង ស្រីម៉ៅ រៀបរាប់ទៀតថា : "លោកតាលោកយាយខ្ញុំ មិនចង់ឱ្យកូនស្រីចេះអាន និងចេះសរសេរទេ ។ ពីសម័យមុនគេខ្លាចកូនស្រីសរសេរសំបុត្រស្នេហា ។ ប៉ុន្តែម្ដាយរបស់ខ្ញុំ ជាអ្នកចង់ចេះ ចង់ដឹង ។ សព្វថ្ងៃគាត់ជំរុញលើកទឹកចិត្តពួកយើង ។ គាត់ចង់ឱ្យយើងរៀនសូត្របានកាន់តែចេះដឹងឡើង១ ប៉ុន្តែនៅពេលដែលគាត់ធ្លាក់ខ្លួនឈឺ ខ្ញុំត្រូវតែធ្វើការចិញ្ចឹមជីវិត" ។

ជាអ្នកលក់សម្លៀកបំពាក់ជជុះ១ អ្នកស្រីហេង ស្រីម៉ៅ ចង់ឱ្យកូនស្រីអាលីហ្សាគាត់ ដែលចង់ក្លាយជាគ្រូពេទ្យ អាចសម្រេចនូវសុបិនរបស់ខ្លួន ។ កូនស្រីគាត់មានដុងតាំងពីកំណើត ។ នាងបង្ហាញឱ្យឃើញតាមរយៈចំណង់ដ៏ខ្លាំងក្លាក្នុងការអានសៀវភៅ ។ នេះគឺជាសញ្ញាដ៏វិជ្ជមានមួយ ។

ពេលវេលាចេះតែរំកិលទៅមុខ អាលីហ្សាត្រូវចាកចេញ នាងរត់សំដៅទៅរកកង់ហើយជិះចេញទៅ ។ រីឯអ្នកស្រីហេង ស្រីម៉ៅ នៅជក់ចិត្តអានសៀវភៅរហូតដល់ពេលដែលបណ្ណាល័យបិទទ្វារ ។

នៅឯជ្រុងម្ខាងទៀត លោកនេនក្មេងមួយអង្គ ព្រះនាម សៀង សុវណ្ណនី បានចំណាយពេលវេលាច្រើនម៉ោងដើម្បីអានសៀវភៅ នៅក្នុងខណៈពេលដែលសាមនេរូបនេះទើបតែរៀនអាន និងរៀនសរសេរក៏កំពុងស្ថិតនៅផងដែរ ។ ជាក្មេងកំព្រាសាមនេតូចរូបនេះ បានរកឃើញសម្រាប់ខ្លួនឯងនូវពិភពផ្ទាល់ខ្លួនជារៀងរាល់ដងដែលបណ្ណាល័យបើកទ្វារ ហើយស្ថិតនៅក្នុងជម្រៅនោះ : គឺជាពិភពនៃអំនាន ។



### "មណ្ឌលអប់រំសម្រាប់ទាំងអស់គ្នា" - (CET)

**បង្កើតឡើងដោយអង្គការ SIPAR ដើម្បីជួយអភិវឌ្ឍចំណេះដឹងប្រជាជនតាមមូលដ្ឋានដាច់ស្រយាល។ ដើម្បីបង្កើតមណ្ឌល ឬបណ្ណាល័យនេះ អង្គការ SIPAR បានសហការជាមួយក្រុមប្រឹក្សាឃុំ។ ការសាងសង់ និងគ្រប់គ្រងមណ្ឌលនីមួយ១ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាឃុំ។ មណ្ឌលមានបំពាក់ឧបករណ៍សិក្សាចំនួន២៥០០ (សៀវភៅផ្ទាំងផ្សព្វផ្សាយអប់រំល្បែងកំសាន្ត-ល-)។ មណ្ឌលនីមួយ១ មានម៉ូតូមួយគ្រឿងដើម្បីធ្វើសកម្មភាពចល័តនៅភូមិឆ្ងាយផងដែរ។ មកទល់នឹងចុង ឆ្នាំ២០០៧នេះ មណ្ឌលអប់រំសម្រាប់ទាំងអស់គ្នាមាន២៨កន្លែងនៅតាមឃុំមួយចំនួន ក្នុងខេត្តក្រចេះ កណ្ដាល ព្រៃវែង កំពង់ចាម និងកំពង់ស្ពឺ។**

January-2008.qxd 1/18/2008 4:18 PM Page 10



# តវ៉ាន់ឡើងថ្លៃជាកង្វល់បន្ថែមរបស់កម្ម ករកាត់ដេរ

អាគីប និងសម្ផស្ស



Photos : L. Samphors

**ក្ដីកង្វល់ពីអតុល្យភាពរវាងប្រាក់ខែ និងទំនិញ**

ស្ថិតនៅក្នុងកូនបន្ទប់តូចមួយ ដែលមានយាំងវាំងននសម្រាប់បិទបាំងកន្លែងគេង និងមានកូនចង្ក្រានតូចមួយនៅក្បែរនោះផងដែរ កំពុងអង្គុយចិតបន្លែ អ្នកនាងលីន ណា អាយុ ២១ឆ្នាំ ដែលទើបនឹងឆ្លងទន្លេ បានកូនស្រីមួយបាននិយាយមកកាន់អ្នកយកព័ត៌មានយើងថា នាងបានធ្វើការនៅរោងចក្រកាត់ដេរសាន់តិច ជាងមួយឆ្នាំមកហើយ ។ អ្នកនាងលីន ណា បានបន្ថែមឱ្យដឹងទៀតថា ក្នុង១ខែ នាងទទួលបានប្រាក់បៀវត្សរ៍ជាង១០០ដុល្លារ ។ ភ្ជាប់ជាមួយនឹងសំឡេងដកដង្ហើមធំ អ្នកនាងលីនណា ហាក់ដូចជាមានការព្រួយបារម្ភខ្លាំងជាមួយនឹងកម្រិតប្រាក់បៀវត្សរ៍នៅទាបដដែល ប៉ុន្តែតម្លៃទំនិញមានការកើនឡើងយ៉ាងខ្លាំង ។ នាងបន្តទៀតថា បើប្រៀបធៀបជាមួយនឹងការចំណាយពេលមុនជាមួយនឹងប្រាក់ខែរបស់នាងប៉ុណ្ណេះ គឺវាគ្រប់គ្រាន់ និងអាចផ្ញើទៅឱ្យឪពុកម្ដាយនៅស្រុកបានទៀត តែក្រោយពេលដែលតវ៉ាន់ទាំងអស់មានតម្លៃថ្លៃ ហើយប្រាក់ខែនៅដដែលនោះ ការចំណាយរបស់នាងមានការលំបាក និយាយរួម ចាយមិនគ្រប់គ្រាន់ ។ លីនណា ត្រូវការចំណាយយ៉ាងហោចណាស់ ពី៦ ទៅ៧ពាន់រៀល ដើម្បីទិញម្ហូបមួយពេល ដែលបានកើនឡើង ២០០០រៀល នៅក្នុងមួយពេលៗ បើប្រៀបធៀបជាមួយនឹងការចំណាយនៅពេលមុន ក្នុងសមាជិកដដែល ។ ម្យ៉ាងទៀតពីមុន នាងអាចមានលទ្ធភាពផ្ញើទៅឱ្យម្ដាយនាងពី៣០ ទៅដល់៥០ដុល្លារ ប៉ុន្តែពេលនេះ នាងអាចផ្ញើតែ ១០ដុល្លារប៉ុណ្ណោះ ។

អង្គុយក្បែរនោះដែរ កញ្ញាសុខនីម អាយុ១៩ឆ្នាំ ជាកម្មករកាត់ដេរ ជាង១ឆ្នាំហើយ ។ មួយថ្ងៃ នាងធ្វើការ ៨ម៉ោង ពីម៉ោង២ ទៅដល់ម៉ោង១០យប់ និងប្រសិនបើនាងធ្វើការបន្ថែមម៉ោង នាងនឹងត្រូវធ្វើពីម៉ោង ៦ល្ងាច ទៅដល់ម៉ោង ៥:៣០ព្រឹក ។ នាងទទួលបាន៧០ដុល្លារ ដែលជាប្រាក់ខែងាប់ ( បើមិនថែមម៉ោង) ។ សុខនីមមានការព្រួយបារម្ភ មិនខុសពីអ្នកនាងលីនណាទេ ទោះបីសព្វថ្ងៃ ការចំណាយសព្វបែបយ៉ាង សម្រេចទៅលើបងស្រីរបស់នាង ក៏ដោយ ។ នាងបានបំភ្លឺឱ្យដឹងថា : "ប្រាក់ខែរបស់ខ្ញុំ ខ្ញុំឱ្យទៅបងស្រីរបស់ខ្ញុំទាំងអស់ ប៉ុន្តែខ្ញុំបានសង្កេតឃើញថា ការចំណាយរបស់គាត់លើការរស់នៅសព្វថ្ងៃនេះមានការលំបាកជាងមុន ដោយសារតែតវ៉ាន់សព្វបែបយ៉ាង មានការកើនឡើងខ្ពស់ ដូចជាភ្លើងពីមុនតម្លៃមិនដល់មួយពាន់រៀលទេ ប៉ុន្តែនៅពេលនេះឡើងដល់ជាងមួយពាន់ ក្នុង ១គីឡូ" ។

**នៅតែប្រឈមមុខនឹងភាពលំបាក**

ទោះបីការងារដែលពួកគេកំពុងធ្វើនេះ អាចធ្វើឱ្យពួកគេទទួលបាននូវប្រាក់ចំណូល ទំនុកបម្រុងបន្ទុកក្រុមគ្រួសារពួកគេបានមួយកម្រិតក៏ពិតមែន ប៉ុន្តែសព្វថ្ងៃនេះ អ្វីដែលពួកគេកំពុងប្រឈមមុខ យ៉ាងខ្លាំង និងមិនដឹងថា ពេលណាអាចដោះស្រាយបាននោះ គឺបញ្ហាទំនិញឡើងថ្លៃ ប៉ុន្តែប្រាក់ចំណូលនៅតែតិច ។ ទាក់ទងជាមួយនឹងបញ្ហានេះ អ្នកស្រីអាត អ៊ាង អាយុ៣៣ឆ្នាំ ដែលធ្វើការ នៅរោងចក្រកាត់ដេររ៉ូស៊ីង អស់រយៈពេល ៧ឆ្នាំមកហើយនោះ មានការព្រួយបារម្ភជាខ្លាំងជាមួយនឹងទំនិញឡើងថ្លៃគ្រប់យ៉ាង ដែលជាហេតុនាំឱ្យគាត់ មានការលំបាកនៅក្នុងការផ្គត់ផ្គង់ជីវភាពសព្វថ្ងៃនេះរបស់គាត់ ។ ងាកមកអង្គុយនៅក្នុងបន្ទប់ជួលតូចមួយ ដែលមានតម្លៃជួល ១៦ដុល្លារ ក្នុងមួយខែ អ្នកស្រីសម្ដែងនូវក្ដីព្រួយបារម្ភ ក្រោមទឹកមុខស្រពោនថា: "សព្វថ្ងៃខ្ញុំរកបានតែមួយពោះ រស់មួយក្រពះតែប៉ុណ្ណោះ" ។ អ្នកស្រីក៏បន្ថែមថា ចំពោះការរស់នៅក្នុងស្ថានភាពដូចសព្វថ្ងៃ ដែលប្រាក់ខែទទួលបាន ពី៦០ ទៅ៧០ដុល្លារ ក្នុង១ខែនោះ គឺមិនអាចហូបគ្រប់គ្រាន់ និងមិនអាចជួយឱ្យអ្នកស្រី សន្សំប្រាក់ខ្លះបានឡើយ ។ អ្នកស្រីរៀបរាប់ដែរថា គាត់ត្រូវចំណាយសព្វបែបយ៉ាងទាំងថ្លៃឈ្នួលបន្ទប់ ថ្លៃទឹក-ភ្លើង ថ្លៃអាហារប្រចាំថ្ងៃ និងប្រាក់ដែលត្រូវផ្ញើទៅចិញ្ចឹមកូននៅឯស្រុកកំណើត ។ អ្នកស្រីអាត អ៊ាង បានសង្កត់ធ្ងន់ថា ទោះបីជាអ្នកស្រី មានប្ដីរត់ម៉ូតូឌុប ជួយរកចំណូលបន្ថែមខ្លះក្ដី ក៏មិនធ្វើឱ្យជីវភាពបានធូរធាដែរដោយសារតែអ្វីៗសព្វគ្រប់បែបយ៉ាងឡើងថ្លៃយ៉ាងនេះ ។

"ដោយសារតែបញ្ហាជីវភាពទើបបានជាខ្ញុំសម្រេចចិត្តមកធ្វើការនៅរោងចក្រដោយក្ដីសង្ឃឹមថា នឹងអាចជួយដល់គ្រួសារ តែការគិតរបស់ខ្ញុំផ្ទុយស្រឡះទៅវិញ ពីព្រោះប្រាក់ខែដែលទទួលបានចាយវាយតែម្នាក់ឯងសឹងតែមិនគ្រាន់ផង" នេះជាសំដីត្អូញត្អែររបស់កញ្ញាចន្ថា ។ ជាមួយនឹងប្រាក់ខែ៥០ដុល្លារ ចន្ថាត្រូវចាយវាយយ៉ាងសន្សំសំចៃបំផុតទើបអាចសល់បានប្រាក់មួយចំនួន ផ្ញើទៅឱ្យម្ដាយនៅស្រុកកំណើត ។ កញ្ញាបន្តទៀតថា សម្រាប់អាហារមួយពេល នាងចំណាយពី៥០០ ទៅ៨០០រៀលប៉ុណ្ណោះ ដោយមិនគិតទៅលើម្ហូបឆ្ងាញ់ ឬមិនឆ្ងាញ់ នោះទេ ឱ្យតែបានឆ្អែតក្រពះ ។ "ប្រាក់ពិបាករក ការងារក៏ពុំសូវសម្បូរដូចពេលកន្លងមក ហើយទំនិញសព្វថ្ងៃក៏ឡើងថ្លៃយ៉ាងគំហុក គឺជាហេតុធ្វើឱ្យជួបប្រទះការលំបាកផ្នែកជីវភាព ។" ការព្រួយបារម្ភរបស់ចន្ថា ។

**សូម្បីតែអាជីវករក៏ពិបាកដែរ !**

សព្វថ្ងៃនេះ មិនថាតែកម្មករកាត់ដេរនោះទេ ដែលកំពុងតែជួបក្ដីកង្វល់ជាមួយនឹងតម្លៃទំនិញ នៅលើទីផ្សារដែលឡើងថ្លៃ ពីមួយថ្ងៃទៅមួយថ្ងៃ ទោះបីជាអាជីវករដែលរង់ចាំតែទទួលអ្នកទិញនោះក៏បានប្រឈមមុខនឹងការថយចុះនូវចំនួនអ្នកទិញផងដែរ ហើយបញ្ហានេះត្រូវបានដោះស្រាយនោះទេ ។ អង្គុយនៅក្នុងតូបលក់អាហារថ្ងៃត្រង់ នៅទល់មុខរោងចក្រស៊ូព្រីម្បៀ ស្ថិតនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ អ្នកស្រីធារីក៏មានការព្រួយបារម្ភមិនខុសពីកម្មករកាត់ដេរនោះដែរ ដោយអ្នកស្រីបានឱ្យដឹងថា ការលក់របស់អ្នកស្រីសព្វថ្ងៃនេះ ជួបប្រទះការលំបាកច្រើនជាងមុន គឺចាប់តាំងពីទំនិញគ្រប់បែបយ៉ាងឡើងថ្លៃមក ពួកគេលក់មិនសូវដាច់ ហើយពុំសូវចំណេញដូចជាពេលមុននោះដែរ ។ អ្នកស្រីបានបន្ថែមទៀតផងដែរថា: "ខ្ញុំក៏តែងឮកម្មករជាច្រើននាំគ្នាត្អូញត្អែរថា តវ៉ាន់ចេះតែឡើងថ្លៃ ហើយងាកមកមើលប្រាក់ខែនៅដដែល ដូច្នេះតើឱ្យពួកគេរស់នៅយ៉ាងម៉េចទៅ?" ។ ប៉ុន្តែឥឡូវនេះកម្មករម្នាក់ៗប្រយ័ត្នណាស់ក្នុងការចាយវាយដោយពួកគេគឺត្រូវសន្សំសំចៃ មិនចាយផ្ដេសផ្ដាស់នោះទេ ។

លោកជាមុន្នី ប្រធានសហជីពសេរីកម្មករនៃកម្ពុជា មានប្រសាសន៍ថា : "ស្ថានភាពកម្មករកាត់ដេរនៅពេលនេះ មិនមានអ្វីខុសប្លែកពីមុនទេ កម្មករគ្មានសិទ្ធិសេរីភាពគ្រប់គ្រាន់ និងគ្មានសេរីភាពបញ្ចេញមតិយោបល់ពេញលេញឡើយ ជាពិសេសនោះ គឺពួកគេក៏នៅទទួលប្រាក់ខែតិចតួចដដែល" ។ លោកបន្ថែមថា ប្រាក់ខែគឺជាជីវិតរបស់ពួកគេពីព្រោះពួកគេមកធ្វើការដើម្បីស្វែងរកប្រាក់ ។ ដូច្នេះសម្រាប់បញ្ហាដែលប្រជាជនកម្ពុជា កំពុងជួបប្រទះនេះ តើរដ្ឋាភិបាល ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធគួរតែចេញវិធានការ ឬដំណោះស្រាយដូចម្ដេច?

## សព្វថ្ងៃនេះ ខ្ញុំរកបានស៊ីតែមួយពោះ រស់មួយក្រពះប៉ុណ្ណោះ

## ការចូលជាសមាជិកសហជីពសេរីកម្មករ?

ការចូលជាសមាជិកសហជីពសេរីកម្មករអាស្រ័យទៅលើកម្មករ-កម្មការិនីកាត់ដេរ យល់ព្រមចូលរួមជាមួយសហជីពយើងឬទេ? បើពួកគេយល់ថា សហជីពសេរីកម្មករអាចគោរពច្បាប់ ការពារសិទ្ធិ និងទាមទារតំឡើងប្រាក់បៀវត្សរ៍បាន គឺពួកគាត់អាចចូលជាសមាជិក។ ម្យ៉ាងទៀតបើពួកគាត់មានធ្វើបាតុកម្ម ឬកូដកម្ម ហើយពឹងពាក់យើង យើងអាចជួយ។ កម្មករក៏អាចបង្កើតសហជីពដោយខ្លួនឯង ឬចូលរួមជាមួយយើង។ សព្វថ្ងៃនេះសហជីពសេរីកម្មករមានសមាជិកចំនួន ៧៨០០០នាក់ ដែលមានទាំងកម្មករនៅមន្ទីរពេទ្យឯកជន កម្មករអគ្គិសនី និងកម្មករបកក្ដាមជាដើម។ នៅឆ្នាំ២០០៤-២០០៦ រោងចក្រកាត់ដេរមានចំនួន ៩១៩ ហើយកម្មករមានពី៣៣ ទៅ៣៤ម៉ឺននាក់។

## អត្រាអតិផរណា ៤,២៧%

**សម្ដេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា អត្រាអតិផរណាជាមធ្យមគិតមកដល់ត្រីមាសទី៣ឆ្នាំនេះកើនឡើងប្រមាណ៤,២៧% បើប្រៀបធៀបនឹងឆ្នាំមុន ប៉ុន្តែអត្រាអតិផរណាម្ហូបអាហារបានកើនលើសនេះបន្តិចក្នុងកម្រិតប្រមាណជា ៦,២៦%។**

| ភាគរយកំណើនទំនិញខ្លះធៀបនឹងឆ្នាំមុន | |
|---|---|
| សាំង | ១១,៣% |
| អង្ករ | ២០% |
| ត្រី | ៣១,៩% |

ទិន្នន័យ : ទស្សនាវដ្ដី Economics Today លេខ០៦/ ១-១៥ មករា ២០០៨

## រោងចក្រកាន់តែប្រសើរនៅកម្ពុជាជាអ្វី?

រោងចក្រកាន់តែប្រសើរនៅកម្ពុជា មានគោលបំណង កែលំអលក្ខខណ្ឌការងាររបស់កម្មករនៅតាមរោងចក្រកាត់ដេរនានានៅកម្ពុជា ដែលធ្វើឱ្យការនាំសម្លៀកបំពាក់ចេញបានកាន់តែល្អប្រសើរ។ ការកែលំអលក្ខខណ្ឌការងារនេះត្រូវបានធ្វើឡើងតាមរយៈការរួមផ្សំរវាងការពិនិត្យដោយឯករាជ្យ និងការស្វែងរកដំណោះស្រាយផ្សេងៗ។ ការរួមផ្សំនេះជាធម្មតាត្រូវបានគេហៅថា វិធីដោះស្រាយ។ វិធីនេះផ្ដើមឡើងដោយការលើកជាសំណូមពរដល់ថ្នាក់គ្រប់គ្រងរោងចក្រ ដើម្បីឱ្យថ្នាក់គ្រប់គ្រងរោងចក្រ បានចុះពិនិត្យធ្វើការបណ្ដុះបណ្ដាលផ្ដល់យោបល់ និងព័ត៌មានដល់កម្មករ ដើម្បីជួយដល់រោងចក្រក្នុងការកែលំអការអនុវត្តន៍ការងាររបស់ខ្លួន។ នេះជាគម្រោងពិសេសមួយបង្កើតឱ្យមានឡើងដោយអង្គការពលកម្មអន្តរជាតិ ដែលនឹងអាចផ្ដល់នូវផលប្រយោជន៍ដល់កម្មករ និយោជិត និយោជក អង្គភាពរោងចក្រ ឬសហគ្រាសរបស់ពួកគេផងដែរ។

January-2008.qxd 1/18/2008 4:19 PM Page 12

**កសិកម្ម**

# ការដាំត្រកួនឱ្យទទួលបានទិន្នផលល្អ

**ដោយស៊ីថា**



Photos: L. Samphhors

ដើម្បីឱ្យត្រកួនដុះលូតលាស់ល្អ យើងត្រូវរើសនូវទីកន្លែងដាំ និងធ្វើរង ឱ្យបានត្រឹមត្រូវស្របតាមរដូវនីមួយៗ។ នៅរដូវប្រាំង ត្រូវតែរើសទីកន្លែងដាំជិតប្រភពទឹកដើម្បីងាយស្រួលស្រោចទឹក និងនៅរដូវវស្សា ត្រូវរកទីកន្លែងដាំនៅលើដីទួលខ្ពស់ មិនលិចទឹក។ មុននឹងដាំ ត្រូវយកជីកំប៉ុស្ត ឬជីលាមកសត្វផ្សេងៗដែលពុកផុយមករោយលើរង ហើយក៏ជ្រៃដីត្រលប់ចុះឡើង ដើម្បីឱ្យជីចូលទៅក្នុងដី និងរាស់ដីឱ្យបានស្មើល្អ។ ដើម្បីឱ្យគ្រាប់ពូជ ដុះបានល្អ យើងត្រូវយកនូវគ្រាប់ពូជណាគ្មានជំងឺ គ្មានការបំផ្លាញពីសត្វល្អិត និងកុំទុកយូរឆ្នាំពេក។ យកគ្រាប់ពូជនេះដាក់សំដិលថ្ងៃ ២ម៉ោង ក្រោមកំដៅស្រទន់ ដើម្បីសម្លាប់មេរោគដែលនៅជាប់នឹងគ្រាប់។ បន្ទាប់មកត្រាំគ្រាប់ពូជ ក្នុងទឹករយៈពេល ១២ម៉ោង រួចត្រូវស្រង់យកក្រណាត់មកខ្ចប់ និងផ្សើមទឹកឱ្យសើមៗជានិច្ចដោយផ្អាប់ទុកពី១ ទៅ២យប់ ដើម្បីឱ្យគ្រាប់ដុះពន្លកទើបយកទៅដាំ។ ដំណាំត្រកួន មិនពិបាកថែទាំទេ គឺយើងគ្រាន់តែដកស្មៅ ស្រោចជី ហើយស្រោចទឹកឱ្យបានគ្រប់គ្រាន់ប៉ុណ្ណោះ ដោយស្រោច ២ដងក្នុង១ថ្ងៃ។ ក្រោយពីដាំ រយៈពេល១៥-២៥ ថ្ងៃ យើងក៏អាចយកផលបាន ដោយយើងអាចដកដោយដៃ ឬអាចប្រើកូនកាំបិតកាត់ក៏បាន។



### ធ្វើដូចម្តេចទើបដាំត្រកួនបានគ្រាប់ពូជល្អ?

យើងអាចដាំត្រកួនយកគ្រាប់ពូជដោយខ្លួនឯងបាន និងមិនចាំបាច់ចំណាយលុយទិញវាទេ។ យើងកុំកាត់ដើមត្រកួន និងត្រូវរក្សាទុកដើមរហូតដល់១-២ខែ រហូតគ្រាប់ត្រកួនទុំល្អ រួចបេះផ្លែត្រកួនយកហាលរយៈពេល២ថ្ងៃ។ ក្នុងរយៈពេលរក្សាដើមត្រកួនដើម្បីយកគ្រាប់ យើងត្រូវបន្តស្រោចទឹក និងធ្វើស្មៅរហូតដល់វាចេញផ្កា ទើបបន្ថយការស្រោចទឹក។ ពេលមានគ្រាប់ហើយ យើងប្រឡេះយកគ្រាប់ចេញ រួចហាលថ្ងៃរយៈពេល ៣០នាទី រួចអុំរោយយកកំទេចកំទីសំរាមចេញ។ ច្រកគ្រាប់ចូលក្នុងដបកែវចុកឆ្នុកឱ្យជិត (ឆ្នុកធ្វើពីស្មៅ ឬស្រកីដូងទុំ) ដើម្បីការពារកុំឱ្យសត្វខ្ចុតស៊ី។ យើងត្រូវជៀសវាងទុកគ្រាប់ពូជត្រកួនយូរឆ្នាំ រួចយកទៅដាំ ដែលធ្វើឱ្យគ្រាប់ពូជមិនស្មើគ្នាល្អ ហើយដើមលូតលាស់យឺត។ គ្រាប់ត្រកួនដែលល្អ គឺទុកពី១ឆ្នាំកន្លះចុះក្រោម និងរក្សាទុកដាក់ឱ្យបានល្អ។

**បរិស្ថាន**

## ជីវឧស្ម័នគាំពារបរិស្ថាន

នៅឆ្នាំ២០០៧ លោកបូជាចារ្យ ប្រ៉ង់ស្វ័រ ប៉ុងសូដឺ ប្រធានមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា បានរៀបចំឱ្យមានឡជីវឧស្ម័នពីរដើម្បីសាកល្បង នៅ



ភូមិចម្លាក់ ឃុំចក ស្រុកអូររាំងឪ ខេត្តកំពង់ចាម ដែលមានអង្គការមកពីប្រទេសហូឡង់ ជាអ្នកជួយខាងបច្ចេកទេស។ លោកបូជាចារ្យមានប្រសាសន៍ថា ក្នុងឡចំនុះ ៨ម៣ យើងបានឧស្ម័នគ្រប់គ្រាន់សម្រាប់ពីរគ្រួសារប្រើប្រាស់ដាំបាយ ចំអិនអាហារ និងដុតចង្កៀងពីរ។ ឡជីវឧស្ម័នមានប្រយោជន៍ច្រើន ដូចជា យើងអាចយកឧស្ម័នមេតានពីលាមកសត្វដែលបំផ្លាញអូហ្សូនមកប្រើប្រាស់ជាថាមពល ដោយមិនចាំបាច់កាប់អុស បំផ្លាញឈើ ឬសាកអាគុយ អស់លុយទេ។ ចំណែកសំណល់ពីឡអាចប្រើប្រាស់ធ្វើជីបានយ៉ាងស័ក្តិសិទ្ធិ។ ដោយឡសាកល្បងបានដំណើរការល្អ នៅឆ្នាំក្រោយ លោកបូជាចារ្យនឹងធ្វើឡ ៤០ទៀត នៅខេត្តកំពង់ចាម។

ឡជីវឧស្ម័នជាសំណង់ឡមូលមួយប្រភេទសង់អំពីឥដ្ឋតាន់ និងបេតុងដែលអាចបង្កើត ឧស្ម័នមេតាន ឬជីវឧស្ម័ន ចេញពីលាមកសត្វ និងទឹក ដោយប្រតិកម្មឡើងក្នុងលក្ខខណ្ឌគ្មានខ្យល់អុកស៊ីសែន។ ជីវឧស្ម័នផ្សំឡើងដោយមេតាន ៥០-៧០% និងឧស្ម័នកាបូនិក ៣០-៤០%។ មេតានជាឧស្ម័នគ្មានក្លិន និងឆេះដោយ បង្កើតជាពន្លឺពណ៌ខៀវថ្លា គ្មានផ្សែង និងគ្មានជាតិពុល។ វាផ្តល់ថាមពលក្តៅជាងប្រេងកាត អុស ឬធ្យូង។ បច្ចុប្បន្ននេះ មានការចាប់អារម្មណ៍យ៉ាងខ្លាំងលើបច្ចេកវិជ្ជាជីវឧស្ម័ន ពីព្រោះវាអាចធ្វើពីសារធាតុកាកសំណល់ដែលមានសម្បូរនៅគ្រប់ទីកន្លែង រួមមានលាមកគោ ក្របី និងជ្រូក ដែលមាននៅស្ទើរគ្រប់ផ្ទះកសិករ។



**សុខភាព**

# ជំងឺមហារីកមាត់ស្បូន



Photos: P. Samphy

**ជាត សំភី**

តាមប្រសាសន៍លោកវេជ្ជបណ្ឌិតតន់ ផល្លី អ្នកឯកទេសវះកាត់ និងរោគស្ត្រីរបស់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងថា:

ជំងឺមហារីកមាត់ស្បូន គឺជាជំងឺមួយដ៏កាចសាហាវ ហើយនៅកម្ពុជា វាឈរលំដាប់ទី១ចំពោះស្ត្រីដែលមានជំងឺមហារីក។ មូលហេតុសំខាន់ដែលបណ្តាលឱ្យមានជំងឺនេះ មានកត្តាបីសំខាន់ៗ គឺទី១បណ្តាលមកពីស្ត្រីនៅក្មេងពេក ហើយឆាប់មានគ្រួសារ ឬឆាប់មានការរួមភេទ ដូចជា ពីអាយុ ១៥ ទៅ១៧ ឆ្នាំជាដើម។ ទី២ គឺបណ្តាល មកពីស្ត្រីមានប្តីច្រើន ឬមានដៃគូរួមភេទច្រើន ដែលដៃគូបុរសគាត់មានដៃគូច្រើនដែរ។ ទី៣ ជំងឺមហារីកមាត់ស្បូន ដែលបណ្តាលមកពីការឆ្លងមេរោគ ដែលជាវីរុស ម្យ៉ាងហៅ HPV ដែលវាធ្វើឱ្យមានការប្រែប្រួលចំពោះកោសិកាមាត់ស្បូន ដែលនេះនាំទៅដល់ការកកើតជាមហារីក។ រោគសញ្ញាសំខាន់របស់ជំងឺមហារីកមាត់ស្បូន គឺស្ត្រីមានអាការៈធ្លាក់ឈាម ធ្លាក់ស ឬមានអាការៈឈឺចាប់ខ្លាំងនៅកន្លែងមហារីក។ បើធ្ងន់ធ្ងរ ជំងឺនឹងលាតសន្ធឹងទៅដល់ផ្លូវតម្រង់នោម វាធ្វើឱ្យពិបាកនោម ដែលនេះគឺជារោគសញ្ញាមួយជ្រុលហួសទៅហើយ។ ដូច្នេះនៅពេលស្ត្រីមានការធ្លាក់ឈាម ឬធ្លាក់ស សំខាន់បំផុត គឺគាត់ត្រូវទៅមន្ទីរពេទ្យធ្វើការតាមដានរកកោសិកាមហារីក និងព្យាបាលឱ្យទាន់ពេលវេលា ព្រោះជំងឺមហារីកមាត់ស្បូន ចែកចេញជាបួនដំណាក់កាល ដែលនៅដំណាក់កាលទី១ គេអាចព្យាបាល ជាសះស្បើយ។ ដំណាក់កាលទីពីរ ការព្យាបាលឱ្យបានជា នៅមានកម្រិត។ ចំណែកឯដំណាក់ទីបី និងទីបួន ព្យាបាលលែងជាហើយ។ ការព្យាបាល មានការវះកាត់នៅដំណាក់កាលទីមួយ ហើយនិងការបាញ់កាំរស្មី និងវះកាត់នៅដំណាក់កាលទីពីរ ដែលត្រូវធ្វើឡើងជាមួយវេជ្ជបណ្ឌិតជំនាញ និងមានបទពិសោធន៍។

ចុងក្រោយ លោកវេជ្ជបណ្ឌិតតន់ ផល្លី បានអំពាវនាវចំពោះបងប្អូនស្ត្រីដែលមានគ្រួសារ ឬមានដៃគូ ហើយ ទោះបីមានសុខភាពល្អធម្មតា ឬមិនមានក៏ដោយ សូមកុំខ្លាច កុំខ្មាស ឬកុំអៀន មកកាន់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលមានកន្លែងពិនិត្យស្រាវជ្រាវ តាមដាន ស្វែងរកនូវកោសិកាមហារីកមាត់ស្បូន ដើម្បីព្យាបាលឱ្យទាន់ពេលវេលា។

## ៤២%

នៃកុមារដែលមានអាយុក្រោម ៥ឆ្នាំនៅឆ្នាំ ២០០០ មានទម្ងន់ក្រោមធម្មតា គឺប្រមាណជា ៥%ច្រើនជាងឆ្នាំ១៩៩៤ នេះបើយោងតាមរបាយការណ៍របស់អង្គការសហប្រជាជាតិ។ ជានិច្ចកាល តាមរបាយការណ៍ ប្រសិនបើមានការរីកចម្រើនត្រូវបានធ្វើឱ្យសម្រេចក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺអេដស៍ ជាទូទៅ ស្ថានភាពនៃសុខភាពកុមារបានធ្លាក់ចុះនៅប្រទេសកម្ពុជា។ អត្រាមរណភាពរបស់កុមារអាយុក្រោម ៥ឆ្នាំ បានកើនឡើងពី១១៥ ទៅ១៤៣ ក្នុងចំណោមកុមារ ១០០០នាក់ ដែលចាប់កំណើតនៅឆ្នាំ២០០៥។ ចំណែកអត្រាមរណភាពរបស់ម្តាយ គឺមានកម្រិតខ្ពស់ណាស់ក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ ជាមួយការស្លាប់របស់ស្ត្រី ៥៤០នាក់ ក្នុងចំណោមស្ត្រី ១០០ ០០០ នៅពេលសម្រាលកូន តែនៅក្រោយឡាវ (៦៦០នាក់)។ នេះគឺជាស្ថិតិដ៏គួរឱ្យបារម្ភមួយ។

# ផ្ទុកអេដស៍ និងមានគភ៌

លោកវេជ្ជបណ្ឌិតឃីម សំអាត ជាអនុប្រធានផ្នែកវេជ្ជសាស្ត្រប្រចាំអង្គការគ្រូពេទ្យគ្មានព្រំដែន មានប្រសាសន៍ថា នៅកម្ពុជាសព្វថ្ងៃ អត្រាឆ្លងមេរោគអេដស៍ចំពោះស្ត្រីមានគភ៌ មាន១,១%។ ហើយបើតាមការស្រាវជ្រាវ ស្ត្រីមានគភ៌ផ្ទុកមេរោគអេដស៍ និងបំបៅកូនដោយទឹកដោះ អាចមានចម្លងមេរោគអេដស៍ទៅដល់កូនក្នុងកម្រិតពី២០ ទៅ៤៥% មានន័យថា ក្នុងចំណោមស្ត្រីមានគភ៌ ១០០នាក់ គឺមានស្ត្រីពី ២០ ទៅ៤៥នាក់ គឺអាចចម្លងមេរោគអេដស៍ទៅកូនបាន។ ផ្ទុយទៅវិញ បើគាត់ពុំបំបៅដោះកូនទេនោះ អត្រាចម្លងមានតែ១៥-៣០% ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ការបំបៅដោះកូន យ៉ាងតិចបំផុតរយៈពេល៦ខែ ក្រោយពេលសម្រាលនៅតែត្រូវបានគេអនុញ្ញាតនៅឡើយ ព្រោះបញ្ហានេះកំពុងត្រូវបានសិក្សាជាសកលថា តើការបំបៅដោះកូនដោយទឹកដោះម្តាយគួរតែជៀសវាងចំពោះស្ត្រីមានគភ៌ និងផ្ទុកមេរោគអេដស៍ ឬអត់?

សូមបញ្ជាក់ផងដែរថា ការចម្លងមេរោគអេដស៍ ពីម្តាយទៅកូនមានបីដំណាក់កាល: ដំណាក់កាលទីមួយ ជាដំណាក់កាលទារកស្ថិតនៅក្នុងផ្ទៃ។ និងទីពីរ គឺជាដំណាក់កាល ម្តាយឈឺពោះសម្រាលកូន ដែលនេះជាដំណាក់កាលមានកម្រិតចម្លងខ្ពស់ជាងដំណាក់កាលដទៃៗទៀត។ ចំណែកទីបីដំណាក់កាលបំបៅដោះកូន។

ទោះបីជាយ៉ាងណាក្តី នៅសព្វថ្ងៃនេះ ប្រជាពលរដ្ឋអាចស្វែងរកនូវវិធីសាស្ត្រថែទាំ ព្យាបាល និងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន បានដែលវិធីសាស្ត្រ គឺត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតា និងទារក របស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។



Picture : Humanity

January-2008.qxd 1/18/2008 4:19 PM Page 14

# ប្រពៃណី



Photo : L. Samphors

## របៀបសំពះខ្មែរ សម្តែងការគោរព និងស្វាគមន៍

**អ្នកនាំសារ**

**ដៃស្វាគមន៍ ឬដៃសូមខមាទោស**

ផ្គុំដៃត្រឹមដើមទ្រូង ចុងម្រាម ក្រោមចង្កាប្រើសម្រាប់មនុស្សមានវ័យបុណ្យស័ក្តិស្មើគ្នា ឬមិត្តភ័ក្រ្ត។ គប្បីលើកដៃសំពះគ្នាទៅវិញទៅមក ដោយដាក់ដៃត្រឹមដើមទ្រូង សម្តែងការស្វាគមន៍ ឬសម្តែងការខមាទោសដោយបញ្ជាក់ ពីផ្លូវចិត្ត ហ៊ានទទួលស្គាល់កំហុស។

**ដៃសំពះ**

ផ្គុំមេដៃត្រឹមចង្កា ចុងម្រាម ក្រោមចុងច្រមុះសម្រាប់អ្នកឋានៈតូច ឬក៏អាយុតិចសំពះអ្នកដែលមានឋានៈខ្ពស់ ឬក៏អ្នកមានអាយុច្រើនជាង។ គប្បីលើកដៃប្រណមដោយផ្គុំមេដៃ ត្រឹមចង្កាចុងម្រាមនៅត្រឹមចុងច្រមុះ។ រីឯអ្នកដែលមានឋានៈ ឬអាយុច្រើន ត្រូវសំពះតបវិញ និងប្រណម្យដៃកម្ពស់ដើមទ្រូង។

**ដៃបង្គំ**

ផ្គុំមេដៃត្រឹមចុងច្រមុះ ចុងម្រាម ដាក់នៅប្រជុំចិញ្ចើមសម្រាប់កូនសំពះឪពុកម្តាយ ចៅសំពះតាយាយ សិស្សសំពះគ្រូ និងរាស្ត្រថ្វាយបង្គំព្រះមហាក្សត្រ។

**ដៃបន្ទូល**

ផ្គុំមេដៃត្រឹមប្រជុំចិញ្ចើម ចុងម្រាមនៅប្រជុំជើងសក់ សម្រាប់ធ្វើការអធិដ្ឋានបួងសួងវត្ថុស័ក្តិសិទ្ធ អ្នកតាទេវតា ព្រះឥន្ទ ព្រះព្រហ្ម... ឬរំលឹកគុណដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។

សំពះអាចធ្វើឡើងនៅពេលឈរអង្គុយ ឬដេកនៅលើគ្រែ ចំពោះមនុស្សឈឺ។ ធម្មតាគេសំពះដោយការឱនក្បាលចុះបន្តិច មិនរឹងកំព្រឹង មិនទទ់ជ្រាយ មិនឃឹត មិនរហ័សពេក និងមិនកញ្ចក់ៗ។ ពេលខ្លះគេសំពះ និងនិយាយប្រើពាក្យគោរពផង គឺតាមកាលៈទេសៈ ឬឋានៈរបស់បុគ្គលដែលយើងជួបប្រាស្រ័យ។ ពេលធម្មតាគេមិនសំពះដោយលើកដៃខ្ពស់ហួសថ្ងាសនោះទេ គឺលើកលែងតែអ្នកទោស ឬអ្នកសុំទានដែលសម្តែងនូវការដឹងគុណ យ៉ាងជ្រាលជ្រៅ ដល់អ្នកដែលមានសន្តោស ឬលើកលែងទោសឱ្យគេ ពោលគឺជាការសម្តែងនូវការដឹងគុណដ៏លើសលុបជាទីបំផុត។ នៅពេលមានអាសន្នអន់ក្រ ភ័យអន្តរាយ ឬការខឹងសម្បានឹងអ្នកណាម្នាក់ រឿងអ្វីមួយ ការសំពះនោះ គេអាចមើលឃើញការលើកដៃប្រណម គឺខ្ពស់ហួសខ្នាត។ បើការភ័យ ឬស្អប់ កាន់តែខ្លាំង ការលើកដៃសំពះបន់ស្រន់នោះ ហៅថាការដាក់បណ្តាសា ដោយលើកដៃកាន់តែខ្ពស់។

## អំណាន

### ជីវិតឥតន័យ




នៅពេលដែល សុទ្ធ ប៉ូលីន និពន្ធរឿង **ជីវិតឥតន័យ** ហើយបោះពុម្ពលើកទី១ នៅឆ្នាំ១៩៦៥ គាត់ប្រហែលជាមិនបានគិតទេថា រឿងនេះនឹងល្បីក្នុងស្រទាប់យុវជននាសម័យនោះ។ ប្រលោមលោកនេះបានល្បីល្បាញព្រោះថា នេះជាស្នាដៃអក្សរសិល្ប៍ ដែលលាតត្រដាងអំពីទំនាស់រវាងវណ្ណៈ និងវណ្ណៈ គឺរវាងវណ្ណៈអ្នកមាន និងអ្នកក្រ។ នៅក្នុងផ្ទៃរឿង តួអង្គ "សារៈ" ជាបញ្ញវន្តក្រខ្សត់ ដែលធ្លាប់រងគ្រោះដោយសារវណ្ណៈ។ ដូច្នេះហើយទើបគេមានគំនិតស្អប់ខ្ពើមអ្នកមានទ្រព្យទូទៅ។ សារៈបានពិចារណាច្រើនជ្រុលទៅលើជីវិត និងបញ្ហាសង្គមនានា។ ប៉ុន្តែថ្ងៃមួយនៅពេលដែលសារៈជួបរតនា ដែលជាកូនស្រីអ្នកមាន តែមិនមានចរិតឆ្មើងឆ្មៃ ដូចអភិជនទូទៅ ជីវិតរបស់គេផ្លាស់ប្តូរទាំងស្រុង។ ដោយសារតែសេចក្តីស្នេហានេះ សារៈអាចរំដោះខ្លួនចេញពីពិភពអស់សង្ឃឹម ចេញពីមនុស្សខ្ពើមជីវិត មកបែរចាប់តោងក្រេបជញ្ជក់រសជាតិជីវិតដែលរតនាផ្តល់ឱ្យ។ នៅទីបំផុត សោកនាដកម្មមួយកើតឡើង ដោយស្នេហានេះមិនអាចសម្រេចដូចបំណង។ ទំនាស់វណ្ណៈនៅតែជាទំនាស់វណ្ណៈ។

### ក្មេងវត្តសម័យបារាំង




ទាក់ទាញអារម្មណ៍អ្នកអាន ទូទៅតាំងពីបើកទំព័រទីមួយមកម្ល៉េះ ព្រោះថា អ្នកនិពន្ធជុត ខៃ ចេះកែច្នៃសោកនាដកម្ម ឬរឿងរ៉ាវកំសត់ផ្សេងៗ ឱ្យទៅជារឿងកំប្លែង ដែលមិនគួរឱ្យនឹកស្មានដល់។ នៅក្នុង រឿងក្មេងវត្តសម័យបារាំង អ្នកនិពន្ធរៀបរាប់អំពីដំណើរជីវិតរបស់ខ្លួន និងមិត្តភក្តិមួយចំនួនទៀត ជាពិសេសអាឆៃ នៅពេលទៅនៅវត្ត នាឆ្នាំ១៩៤៧។ ក្មេងវត្តទាំងនោះរស់នៅក្នុងកុដជាមួយគ្នា ជាក្រុមៗ។ ពួកគេច្រើនខិល ហើយប្រព្រឹត្តរឿងដែលគួរឱ្យអស់សំណើចជាច្រើន ដូចជាជុះអាចម៍ដាក់កុដ លួចចង្ហាន់លោក ជក់មើលល្ខោន ឬទាស់គ្នាព្រោះដណ្តើមសំណែនអ្នកតាជាដើម។ លើសពីនេះទៀតពួកគេក៏ត្រូវជួបនឹងសេចក្តីឃ្លាន កង្វះអនាម័យ ការវាយតប់ និងការតឹងរ៉ឹងរបស់ព្រះសង្ឃដែរ។ ក្រោយមកទៀត ក្មេងៗមួយចំនួនត្រូវចូលរៀននៅសាលាបារាំង ដែលនៅទីនោះហើយ ដែលពួកគេបានប្រឈមមុខនឹងគ្រូកាចៗ ហើយនៅពេលចូលដល់វ័យជំទង់ ពួកគេក៏ជួបស្នេហាគ្រាដំបូង និងស្គាល់ជីវិតពេញវ័យមុននឹងការមកដល់នៃរបបខ្មែរក្រហម ។



# ប្រវត្តិសាស្ត្រ

## ប៉ាគីស្ថានចាប់កំណើតដោយក្តីឈឺចាប់

**អ្នកនាំសារ**




ពេលសង្គ្រាមលោកលើកទីពីរបានបញ្ចប់ ប្រទេសអង់គ្លេសលែងមានមធ្យោបាយដើម្បីរក្សាចក្រភពអាណានិគមរបស់ខ្លួនទៅលើប្រទេសឥណ្ឌាទៀតហើយ ព្រោះថាការតស៊ូរបស់ប្រជាជនឥណ្ឌានិយមឯករាជ្យបានកើតមានឡើងតាំងពីមុននេះច្រើនឆ្នាំមកហើយ។ ទន្ទឹមនឹងនេះក៏កកើតមានអំពើហិង្សាសម្លាប់គ្នាទៅវិញទៅមករវាងប្រជាជនកាន់ហិណ្ឌូសាសនា និងឥស្លាមសាសនាផងដែរ ដែលនេះបានបណ្តាលឱ្យមនុស្សរាប់ពាន់នាក់ ស្លាប់បាត់បង់ជីវិត ដែលបង្ខំឱ្យប្រជាជនអង់គ្លេសបែងចែកទឹកដីឥណ្ឌាជា២ មានប្រទេសឥណ្ឌាសព្វថ្ងៃ ដែលមានប្រជាជនច្រើនលើសលប់ជាហិណ្ឌូសាសនិក ហើយនិងទឹកដីមួយទៀត ដែលប្រជាជនភាគច្រើន គឺជាអ្នកកាន់សាសនាឥស្លាម។ ទឹកដីទីពីរនេះហើយ ជាប្រទេសប៉ាគីស្ថានដែលចាប់កំណើតឡើង ក្នុងឆ្នាំ១៩៤៧។ នៅខណៈនោះដែរប្រទេសប៉ាគីស្ថាន ត្រូវបែងចែកជាពីរទៀត គឺប៉ាគីស្ថានខាងលិច និងប៉ាគីស្ថាន ខាងកើត (បង់ក្លាដេសសព្វថ្ងៃ) ដែលនៅអមសងខាងប្រទេសឥណ្ឌា។ ការបែងចែកនេះនាំមកនូវចលនាបំផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកាន់សាសនាទាំងពីរដ៏ធំសម្បើម ដែលចលនានេះក៏បាននាំមកនូវការកាប់សម្លាប់គ្នារវាងប្រជាជនសហគមន៍ទាំងពីរ។ នេះគឺជាព្រឹត្តិការណ៍នៃការចំណាកស្រុក ដ៏ធំបំផុតប្រចាំនៅសតវត្សរ៍ទី២០ !

ទោះជាយ៉ាងនេះ ការបែងចែកក៏មិនបានបញ្ចប់នូវបញ្ហាដែរ។ ខេត្តនៅភាគខាងលិចឥណ្ឌា គឺកាស្មៀ ដែលមានប្រជាជនសាសនិកឥស្លាម ភាគច្រើន រស់នៅបានក្លាយជាប្រភពជម្លោះយោធារវាងប្រទេសប៉ាគីស្ថាន និងប្រទេសឥណ្ឌា។ ក្រោយអំពីមានបទឈប់បាញ់ ដែលត្រូវបានគេចុះហត្ថលេខាកាលពីឆ្នាំ១៩៤៩ សង្គ្រាមបានកើតមានជាថ្មីនៅឆ្នាំ១៩៦៥។ ហើយសព្វថ្ងៃ ទំនោរទៅរកសង្គ្រាមនៅរស់រវើក។ ប្រទេសទាំងពីរតែងតែសន្ទនាគ្នា។

ប៉ុន្តែព្រឹត្តិការណ៍នៅឆ្នាំ១៩៧១ គឺមានជម្លោះដែលនាំទៅដល់ការប្រកាសឯករាជ្យពីប្រទេសប៉ាគីស្ថាន គឺការប្រកាសឯករាជ្យនូវខេត្តភាគខាងកើត ដែលក្រោយមកត្រូវបានហៅថា ប្រទេសបង់ក្លាដេស។



Photo : DR

### តើនរណាជា បេណាហ្សៀ ប៊ូតូ?

**គឺជាមេដឹកនាំនយោបាយស្ត្រីនៅគណបក្សប្រឆាំង គឺគណបក្សប្រជាជនប៉ាគីស្ថាន។ លោកស្រីត្រូវបានគេធ្វើឃាតកាលពីថ្ងៃទី២៧ ធ្នូ ២០០៧កន្លងទៅនេះ។ លោកស្រីធ្លាប់ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីច្រើនសា នៅឆ្នាំ១៩៨៨ បន្ទាប់ពីគណបក្សរបស់លោកស្រីបានទទួលជ័យជម្នះនៅក្នុងការបោះឆ្នោត និងរហូតដល់ឆ្នាំ១៩៩០ ហើយត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីម្តងទៀតពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦។ នៅឆ្នាំ១៩៩៧ លោកស្រីត្រូវបានចោទប្រកាន់ដោយអាជ្ញាធរប៉ាគីស្ថានពីបទពុករលួយ ហើយត្រូវបានគេនិរទេសខ្លួន។ ក្រោយពីរួចទោស អ្នកស្រីបានត្រឡប់មកវិញនៅចុងឆ្នាំ២០០៧ ដើម្បីចូលរួមការបោះឆ្នោតនាខែមករា ឆ្នាំ២០០៨។ មនុស្សជាច្រើនធ្លាប់សង្ឃឹមថា លោកស្រីបេណាហ្សៀ ប៊ូតូ នឹងប្រមូលអ្នកគាំទ្រសម្រាប់គណបក្សលោកស្រីពីក្រុមមនុស្សដែលមិនត្រូវការលទ្ធិផ្តាច់ការយោធា និងក្រៅពីក្រុមជនឥស្លាមជ្រុលនិយម ដើម្បីដឹកនាំប្រទេស។**

សម្រាប់ប្រទេសប៉ាគីស្ថាន នយោបាយការបរទេសពោរពេញដោយភាពចលាចល និងមានភាពស្មុគ-ស្មាញ ដែលបណ្តាលមកពីប្រទេសនេះធ្លាប់មានរដ្ឋប្រហារយោធាជាច្រើនសា នៅឆ្នាំ១៩៥៨ ១៩៧៧ និងនៅឆ្នាំ១៩៩៩។ តែបើនិយាយជារួម មេដឹកនាំនយោបាយ ជួនកាលក៏ទទួលបានជោគជ័យក្នុងការកែលំអកម្រិតជីវភាព ប្រចាំថ្ងៃ របស់ប្រជាជនផងដែរដែលសព្វថ្ងៃនេះមានជិត ១៦៥លាននាក់។ តែពួកគេមានភាពបរាជ័យ ក្នុងការដោះស្រាយបញ្ហាពុករលួយ ការជួញដូរគ្រឿងញៀន និងអាវុធ ព្រមទាំងជម្លោះ ឬការប្រណាំងប្រជែងរវាងសហគមន៍ខុសៗគ្នា។ ហើយភាពតានតឹងទាំងនេះ ក៏ត្រូវបានដាក់ទម្ងន់បន្ថែមដោយសារតែទីតាំងយុទ្ធសាស្ត្ររបស់ប្រទេសប៉ាគីស្ថាននៅក្នុងតំបន់។ ប្រទេសនេះគឺមានទំហំធំជាងប្រទេសកម្ពុជាប្រហែលជិត ៤,៥ ដង និងក៏មានព្រំប្រទល់ជាប់ជាមួយប្រទេសអ៊ីរ៉ង់ ប្រទេសអាហ្គានីស្ថាន និងប្រទេសឥណ្ឌា។ ចំណែកប្រទេសអាមេរិកបានចាប់អារម្មណ៍យ៉ាងក្បៀកកិតជាមួយនឹងការវិវត្តនៃប្រទេសប៉ាគីស្ថាន និងក៏ជួយផ្តល់ហិរញ្ញវត្ថុឱ្យដល់ប្រទេសនេះទៀតផង។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី នៅក្នុងសាធារណៈរដ្ឋឥស្លាមដែលដឹកនាំដោយក្រុមយោធានេះ គឺមានជនជ្រុលនិយម ដែលពោរពេញទៅដោយអំណាច ចំណែកប្រជាធិបតេយ្យមានការវិវត្តន៍តិចតួចប៉ុណ្ណោះ។

January-2008.qxd 1/18/2008 4:20 PM Page 16

# ពាក្យខ្វែង ល្បែងកំសាន្ត

អ្នកកំលោះឆ្លាតនៅក្នុងរឿង "ឪពុកក្មេករើសកូនប្រសា" មិនមានឈ្មោះទេ។ តើប្អូនអាចជួយដាក់ឈ្មោះឱ្យគាត់បានឬទេ? សូមបំពេញតារាងខាងក្រោមដោយប្រើពាក្យទាំងឡាយដែលជាសំភារៈប្រើប្រាស់ចាំបាច់នៅក្នុងការរៀនសូត្រនៅសាលារបស់ប្អូន។



## គម្រោងការប្រចាំខែ

- រៀងរាល់ថ្ងៃសៅរ៍ : ព្រះសហគមន៍កាតូលិកនៅក្រុងព្រះសីហនុមានបង្ហាត់ភ្លេងដល់កុមារចំនួន២០នាក់ ដើម្បីឱ្យពួកគេអាចលេងនៅក្នុងពិធីថ្វាយអភិបូជា ឬពិធីបុណ្យផ្សេងៗ ដែលកើតមានឡើងនៅក្នុងព្រះសហគមន៍កាតូលិក។
- ថ្ងៃទី១៤-១៨ មករា : មានការប្រជុំគ្រូអប់រំជំនឿមនុស្សពេញវ័យទាំងបីភូមិភាគនៅក្រុងព្រះសីហនុ ដើម្បីពិភាក្សាអំពីសៀវភៅអប់រំជំនឿថ្មី ចេញផ្សាយដោយមណ្ឌលវប្បធម៌កាតូលិក។
- នៅពាក់កណ្តាលខែមករា : គ្រូពេទ្យធ្មេញស្ម័គ្រចិត្តមកពីប្រទេសបារាំង និងខ្មែរ មកព្យាបាលជូនប្រជាជនរយៈពេល១០ថ្ងៃ នៅព្រះសហគមន៍ចម្លាក់ ខេត្តកំពង់ចាម។
- ថ្ងៃទី២២ មករា : មានការជួបប្រជុំរបស់បូជាចារ្យភូមិភាគភ្នំពេញ វេលាម៉ោង ៨:៣០នាទីព្រឹក និងមានការធ្វើសំណាក់ធម៌កន្លះថ្ងៃនៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី២៣ មករា : ប្រជុំបូជាចារ្យអប់រំជំនឿនៅព្រះសហគមន៍កាតូលិកកំពង់ចាម។
- ពីថ្ងៃទី២៥ មករា ដល់ថ្ងៃទី៧ កុម្ភៈ ឆ្នាំ២០០៨ : មានសិក្ខាសាលាម៉ាជីសនៅប្រទេសឥណ្ឌា ដែលរៀនអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដែលមានអ្នកចូលរួម ៨នាក់ និងដឹកនាំដោយលោកបូជាចារ្យហ្គាប៊ីនៅភូមិភាគបាត់ដំបង។
- ថ្ងៃទី២៧ មករា : ពិធីជំហានទី១ នៃអគ្គសញ្ញាជ្រមុជទឹករបស់បងប្អូនចំនួន ១៥នាក់ ជាអ្នកស្វែងយល់នៅព្រះសហគមន៍សន្តយ៉ូសែប ។
- ថ្ងៃទី០៦ កុម្ភៈ : បុណ្យរោយផេះ។
- ថ្ងៃទី១០ កុម្ភៈ : ពិធីជំហានទី២ នៃអគ្គសញ្ញាជ្រមុជទឹករបស់បងប្អូនស្វែងយល់នៅព្រះសហគមន៍សន្តយ៉ូសែប ចំនួន១៦នាក់។
- ថ្ងៃទី១០ កុម្ភៈ : ការអធិដ្ឋានតេហ្សេដែលដឹកនាំដោយក្រុមយុវជន នៅព្រះវិហារកាតូលិកសន្តយ៉ូសែប វេលាម៉ោង ៦ល្ងាច។
- ថ្ងៃទី១៧ កុម្ភៈ : ពិធីសំណាក់ធម៌របស់គ្រីស្តបរិស័ទ ធ្វើពីពីម៉ោង៥:៣០-៧:៣០នាទីយប់នៅព្រះសហគមន៍សន្តយ៉ូសែប។
- ថ្ងៃទី១៩ កុម្ភៈ : ប្រជុំបូជាចារ្យភូមិភាគភ្នំពេញដើម្បីរៀបចំគម្រោងការប្រចាំខែនៅព្រះវិហារសន្តយ៉ូសែបរាជធានីភ្នំពេញ។

ប្អូនៗអាចរៀនគូររូបសត្វដំរី និងស្វា ដែលជាសត្វរស់នៅក្នុងព្រៃតាមដំណាក់កាលនីមួយៗ ដូចខាងក្រោមនេះ។

ដំរី



ស្វា

